សេចក្ដីព្រាងទីបួន

# យុទ្ធសាស្ត្រវេជប្ញកជាតិ

ក្របមុខ

**Due date for fourth draft:**

**21 August 2015**

សារ

របស់

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

DRAFT

# អារម្ភកថា

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន

DRAFT

## សេចក្តីថ្លែងអំណរគុណ

រាជរដ្ឋាភិបាលកម្ពុជា សូមសំដែងអំណរគុណដ៏ស្មោះស្ម័គ្រចំពោះក្រសួង និងស្ថាប័នជាតិ ដៃគូអភិ វឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានសិក្សាស្រាវជ្រាវ វិស័យឯកជន និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានផ្តល់វិភាគទានដល់ការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិកម្ពុជា(NRS)។

យុទ្ធសាស្ត្ររេដបូកជាតិកម្ពុជា ត្រូវបានរៀបចំឡើងក្រោមការសម្របសម្រួលជារួមដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការចូលរួមយ៉ាងសកម្មពីក្រសួងបរិស្ថាន និងការណែនាំដ៏មានតម្លៃពីក្រុមការងាររេដបូកកម្ពុជា ក្រុមបច្ចេកទេស ក្រុមប្រឹក្សាយោបល់ និងក្រុមយេនឌ័រ។ ការចូលរួមនេះ បានធ្វើឲ្យយុទ្ធសាស្ត្រជាតិរេដបូកកម្ពុជាកាន់តែមានសង្គតិភាព និងស៊ីគ្នាជាមួយផែនការដែលមានស្រាប់តាមវិស័យនានារបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធ។ សំណើ និងយោបល់នានាដែលទទួលបានពីអ្នកពាក់ព័ន្ធទាំងនៅថ្នាក់មូលដ្ឋាន ថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ តាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ជាបន្តបន្ទាប់ បានផ្តល់ការណែនាំជាយុទ្ធសាស្ត្រសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្ររេដបូកជាតិកម្ពុជា។ មានការគាំទ្រដ៏ទូលំទូលាយផងដែរលើផ្នែកបច្ចេកទេស ពីអ្នកជំនាញជាតិ និងអន្តរជាតិជាច្រើនសម្រាប់ការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ នេះ។

ការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិកម្ពុជា ត្រូវបានគាំទ្រហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ពោលគឺ កម្មវិធីរបស់អង្គការសហប្រជាជាតិស្តីពីការកាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើក្នុងប្រទេសកំពុងអភិវឌ្ឍន៍ (UN-REDD Programme) មូលនិធិភាពជាដៃគូកាបូនព្រៃឈើនៃធនាគារពិភពលោក (FCPF) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP ) និងដៃគូអភិវឌ្ឍន៍ជាច្រើនទៀត។

## ការបដិសេធ

សេចក្តីព្រាងលើកទីបួននៃយុទ្ធសាស្ត្ររេដបូកជាតិកម្ពុជា ត្រូវបានរៀបរៀងឡើងដោយ លោក **ងួន ភក្តី** មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយសហការជាមួយលោក **ឈុន ឌីលុច** មកពីរដ្ឋបាលព្រៃឈើ។ ត្រូវចាត់ទុកយុទ្ធសាស្ត្ររេដបូកជាតិ ជាឯកសាររស់ដែលមានន័យថា ផ្នែកនានានៃយុទ្ធសាស្ត្រនេះអាចនឹងត្រូវកែសម្រួលបន្ថែមទៀត។

## មាតិកា


**សាររបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ..... i
**អារម្ភកថា** ..... ii
**សេចក្ដីថ្លែងអំណរគុណ** ..... iii
**បញ្ជីពាក្យបំព្រួញ និងអក្សរកាត់** ..... vi
**សេចក្ដីសង្ខេប** ..... 1
**១. សេចក្ដីផ្ដើម** ..... 5
១.១ រេដបូកនៅកម្រិតអន្តរជាតិ ..... 5
១.២ រេដបូកនៅកម្ពុជា ..... 6
**២. ចក្ខុវិស័យ** ..... 9
**៣. បេសកកម្ម** ..... 9
**៤. គោលបំណង** ..... 9
**៥. ក្របខណ្ឌយុទ្ធសាស្ត្រ** ..... 9
៥.១ គោលការណ៍ណែនាំ ..... 9
៥.២ ការវិភាគជាយុទ្ធសាស្ត្រ ..... 10
ការបន្ស៊ីជាមួយគោលបំណង និងអាទិភាពដទៃទៀតនៃការអភិវឌ្ឍជាតិ ..... 10
ទិដ្ឋភាពរួមនៃការគ្រប់គ្រងដីព្រៃនៅកម្ពុជា ..... 11
បុព្វហេតុនៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើនៅកម្ពុជា ..... 12
ការចាត់កត្តានានាជាអាទិភាពដែលត្រូវដោះស្រាយតាមរយៈយុទ្ធសាស្ត្ររេដបូកជាតិ ..... 13
៥.៣ គោលបំណងនៃយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រ ..... 15
គោលបំណងយុទ្ធសាស្ត្រទី ១៖ កែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានព្រៃឈើ ..... 15
គោលបំណងយុទ្ធសាស្ត្រទី ២៖ លើកកម្ពស់ការប្រមូលផលព្រៃឈើដោយនិរន្តភាព ..... 16
គោលបំណងយុទ្ធសាស្ត្រទី ៣៖ ពង្រឹងសមត្ថភាពដើម្បីពិនិត្យតាមដានធនធានព្រៃឈើ ..... 16
គោលបំណងយុទ្ធសាស្ត្រទី ៤៖ បង្កើនសមត្ថភាព ចំណេះដឹង ការយល់ដឹង និងលើកកម្ពស់ការចូលរួមរបស់អ្នកពាក់ព័ន្ធ និងផលប្រយោជន៍សម្រាប់អ្នកពាក់ព័ន្ធ ..... 17
**៦. សកម្មភាព** ..... 17
៦.១ ដំណាក់កាលនានាសម្រាប់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ..... 17


DRAFT

រយៈពេលខ្លីចំពោះមុខ (ឆ្នាំ ២០១៦)៖ ការរៀបចំផែនការសកម្មភាពរេដបូក ............... 18
រយៈពេលមធ្យម (ឆ្នាំ ២០១៦-២០២០)៖ ការអនុវត្តផែនការសកម្មភាពរេដបូក ........... 18
រយៈពេលវែង(ក្រោយឆ្នាំ ២០២០)៖ ដំណាក់កាលទូទាត់ហិរញ្ញវត្ថុផ្អែកលើលទ្ធផល... 20
៦.២ ក្របខណ្ឌវ៉ស៌រ(Warsaw)សម្រាប់រេដបូក ........................................................ 21
៦.២.១ ប្រព័ន្ធព័ត៌មានធានាសុវត្ថិភាព (SIS)........................................................... 21
៦.២.២ ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ (NFMS) ........................................... 24
៦.២.៣ កម្រិតបំភាយយោងព្រៃឈើ (FREL/ FRL)..................................................... 29
៦.៣ ការរៀបចំស្ថាប័ន និងការសម្របសម្រួល.......................................................... 31
៦.៣.១ ការរៀបចំស្ថាប័នមានស្រាប់ សម្រាប់ត្រួតពិនិត្យលើការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ ............................................................................................................ 31
៦.៣.២ ការរៀបចំស្ថាប័នសម្រាប់ត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ........ 32
គណៈកម្មាធិការរេដបូកជាតិ (NRC)................................................................. 33
មុខងាររបស់គណៈកម្មាធិការរេដបូកជាតិ ......................................................... 33
**៧. ធនធានហិរញ្ញវត្ថុ**..................................................................................... 35
៧.១ វិធីសាស្ត្រ៖ វិធីផ្អែកលើមូលនិធិ...................................................................... 35
ការបង្កើតទីភ្នាក់ងារជាតិផ្តល់មូលនិធិរេដបូក ........................................................ 36
តួនាទីរបស់ទីភ្នាក់ងារជាតិផ្តល់មូលនិធិរេដបូក ...................................................... 36
៧.២ គោលការណ៍នានា ........................................................................................ 37
៧.៣ យន្តការគណនេយ្យភាពរបស់ទីភ្នាក់ងារជាតិផ្តល់មូលនិធិរេដបូក ......................... 38
**៨. តាមដានត្រួតពិនិត្យ និងវាយតម្លៃ** ................................................................. 38
៨.១ គោលការណ៍នានា ........................................................................................ 39
៨.២ វិធីសាស្ត្រ ...................................................................................................... 40
៨.៣ ការគ្រប់គ្រង និងការរៀបចំស្ថាប័នសម្រាប់ការអនុវត្ត ........................................ 41
**៩. សេចក្តីសន្និដ្ឋាន** ......................................................................................... 41
**១០. ឧបសម្ព័ន្ធ**................................................................................................ 43
ឧបសម្ព័ន្ធ ១៖ តារាង និងរូបដែលមាននៅក្នុងអត្ថបទ ............................................ 43
**កំណត់សំគាល់**............................................................................................... 60

DRAFT

# បញ្ជីពាក្យបំព្រួញ និងអក្សរកាត់

| | | |
|---|---|---|
| BUR | Biannual Update Report | របាយការណ៍បច្ចុប្បន្នភាពរៀងរាល់២ឆ្នាំម្តង |
| COP | Conference of the Parties | សន្និសីទនៃបណ្តាភាគី |
| ELCs | Economic Land Concessions | សម្បទានដីសេដ្ឋកិច្ច |
| ER | Emissions Reduction | ការកាត់បន្ថយការបំភាយឧស្ម័ន |
| FA | Forestry Administration | រដ្ឋបាលព្រៃឈើ |
| FCPF | Forest Carbon Partnership Facility | មូលនិធិភាពជាដៃគូកាបូនព្រៃឈើ |
| FiA | Fisheries Administration | រដ្ឋបាលជលផល |
| GHG | Greenhouse Gas | ឧស្ម័នផ្ទះកញ្ចក់ |
| GRM | Grievance Redress Mechanism | យន្តការដោះស្រាយបណ្តឹងសារទុក្ខ |
| IPCC | Intergovernmental Panel on Climate Change | គណៈកម្មាធិការអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoE | Ministry of Environment | ក្រសួងបរិស្ថាន |
| MRV | Monitoring, Measurement, Reporting and Verification | ការពិនិត្យតាមដាន ការវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ |
| M&E | Monitoring and Evaluation | ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ |
| NC | National Communication | របាយការណ៍ជាតិ |
| NCSD | National Council for Sustainable Development | ក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍដោយចីរភាព |
| NFI | National Forest Inventory | សារពើភណ្ឌព្រៃឈើជាតិ |
| NFMS | National Forest Monitoring System | ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ |
| NFP | National Forest Programme | កម្មវិធីព្រៃឈើជាតិ |
| NGOs | Non-Governmental Organizations | អង្គការមិនមែនរដ្ឋាភិបាល |
| NPASMP | National Protected Areas Strategic Management Plan | ផែនការយុទ្ធសាស្រ្តជាតិគ្រប់គ្រងតំបន់ការពារធម្មជាតិ |
| NRC | National REDD+ Committee | គណៈកម្មាធិការរេដបូកជាតិ |
| NRS | National REDD+ Strategy | យុទ្ធសាស្រ្តរេដបូកជាតិ |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ |



DRAFT

| | | |
|---|---|---|
| PLRs | Policies, Laws and Regulations | គោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិ |
| REDD+ | Reducing Emissions from Deforestation and forest Degradation, conservation of forest carbon stocks, sustainable management of forests, and enhancement of forest carbon stocks | កាត់បន្ថយការបំភាយពីការបាត់បង់ព្រៃឈើ និងការ រេចរឹលព្រៃឈើ ការអភិរក្សកាបូនស្តុកព្រៃឈើ ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងការបង្កើន កាបូនស្តុកព្រៃឈើ |
| FREL/FRL | Forest Reference Emission Level/ Forest Reference Level | កម្រិតបំភាយយោងព្រៃឈើ/កម្រិតយោងព្រៃឈើ |
| RBP | Results-based Payment | ការទូទាត់ផ្អែកតាមលទ្ធផល |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| SIS | Safeguards Information System | ប្រព័ន្ធព័ត៌មានធានាសុវត្ថិភាព |
| SLCs | Social Land Concessions | សម្បទានដីសង្គមកិច្ច |
| SPFF | Strategic Planning Framework for Fisheries | ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល |
| UNFCCC | United Nations Framework Convention on Climate Change | អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| UN-REDD | United Nations Collaborative Programme on Reducing Emissions from Deforestation and Forest Degradation in Developing Countries | កម្មវិធីសហប្រត្តិបត្តិការនៃអង្គការសហប្រជាជាតិស្តីពីការកាត់បន្ថយការបំភាយពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើក្នុងប្រទេសកំពុងអភិវឌ្ឍន៍ |
| UNDP | United Nations Development Programme | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |

DRAFT

## សេចក្តីសង្ខេប

រាជរដ្ឋាភិបាលកម្ពុជាគាំទ្រយ៉ាងមុតមាំចំពោះការរៀបចំ និងការអនុវត្តរេដបូក ដែលជាជម្រើសមួយដើម្បីកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីវិស័យព្រៃឈើ រួមចំណែកចំពោះការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងលើកកម្ពស់ការផ្លាស់ប្តូរទៅរកការអភិវឌ្ឍបៃតង។ គោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងផែនការអភិវឌ្ឍន៍ជាតិដែលមានស្រាប់នានារបស់កម្ពុជា បានរួមបញ្ចូលរេដបូកជាផ្នែកមួយនៃរបៀបវារៈជាយុទ្ធសាស្ត្ររបស់ខ្លួន។ ដោយគោរពតាមសេចក្តីសម្រេចនៃភាគីក្នុងអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ការអនុវត្តរេដបូកនៅកម្ពុជា ចែកចេញជាបីដំណាក់កាលជាបន្តបន្ទាប់ដូចតទៅ៖ ដំណាក់កាលត្រៀមលក្ខណៈ ដំណាក់កាលអនុវត្ត និងដំណាក់កាលទូទាត់ផ្អែកតាមលទ្ធផល (RBP)។ បច្ចុប្បន្ន កម្ពុជាកំពុងស្ថិតនៅចុងដំណាក់កាលនៃការត្រៀម ខ្លួន និងគ្រោងឈានបន្តទៅក្នុងដំណាក់កាលអនុវត្តយុទ្ធសាស្ត្រចាប់ពីឆ្នាំ២០១៦តទៅ។ ដើម្បីធ្វើបែបនេះបាន ក្របខណ្ឌទីក្រុងវ៉ស៊័រសម្រាប់រេដបូកចែងថា កម្ពុជាត្រូវមានធាតុផ្សំដែលពាក់ព័ន្ធជាមួយគ្នាចំនួនបួន៖ (១) យុទ្ធសាស្ត្រជាតិ ឬផែនការសកម្មភាពរេដបូកជាតិ (NRS) (២) ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ (NFMS) (៤) កម្រិតយោងការបំភាយពីព្រៃឈើ/កម្រិតយោងព្រៃឈើ (FREL/FRL) និង (៤) ប្រព័ន្ធព័ត៌ិធានាសុវត្ថិភាពរេដបូក(SIS)។

ដោយគោរពតាមគោលការណ៍ណែនាំរបស់គណៈរដ្ឋមន្ត្រី យុទ្ធសាស្ត្ររេដបូកជាតិកម្ពុជាត្រូវបានរៀបរៀងឡើង អនុលោមតាមជំហាននានា ដែលរួមទាំង ការវិភាគគោលនយោបាយ និងអាទិភាពអភិវឌ្ឍន៍របស់ជាតិនាពេលបច្ចុប្បន្ន និងអនាគត ការបង្កើតចក្ខុវិស័យ បេសកកម្ម និងគោលបំណងនានា ការបង្កើតក្របខណ្ឌយុទ្ធសាស្ត្រដែលផ្សំដោយគោលបំណងនៃយុទ្ធសាស្ត្រ និងសកម្មភាពជាយុទ្ធសាស្ត្រ ការកំណត់អត្តសញ្ញាណកម្ម ការរៀបចំស្ថាប័ន ក្របខណ្ឌ និងយន្តការអនុវត្ត ការវិភាគធនធានហិរញ្ញវត្ថុ និងការរៀបចំក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ។ ចក្ខុវិស័យ បេសកកម្ម និងគោលដៅនៃយុទ្ធសាស្ត្រ រេដបូកជាតិ ត្រូវបានរៀបចំឡើងដោយផ្អែកលើការវិភាគសមត្ថភាពស្ថាប័ន បទពិសោធន៍កន្លងមក និងបច្ចុប្បន្ន ក្នុងការគ្រប់គ្រងដីព្រៃឈើ គោលបំណងនៃយុទ្ធសាស្ត្រ និងសកម្មភាពជាយុទ្ធសាស្ត្រ ដើម្បីដោះស្រាយបុព្វហេតុនៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ។

**ចក្ខុវិស័យ៖** កម្ពុជារួមចំណែកក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅកម្រិតជាតិ និងកម្រិតពិភពលោក តាមរយៈការកែលម្អការអនុវត្តនៅក្នុងការគ្រប់គ្រងព្រៃឈើ ការអភិរក្សជីវចម្រុះ និងការអភិវឌ្ឍបៃតង។

**បេសកកម្ម៖** ការកែលម្អមុខងារ និងសមត្ថភាពរបស់ស្ថាប័នគ្រប់គ្រងព្រៃឈើនៅ

DRAFT

ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងស្ថាប័នពាក់ព័ន្ធរបស់ខ្លួន ដើម្បីពង្រឹងការអនុវត្តគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិនានាដែលមានស្រាប់ ជាពិសេស ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ដើម្បីសម្រេចបានការអភិវឌ្ឍបៃតង និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

**គោលបំណង៖**

១. កាត់បន្ថយការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ ទន្ទឹមនឹងការលើកកម្ពស់ការអភិវឌ្ឍប្រកប ដោយចីរភាព ការអភិរក្ស និងការបង្កើនកាបូនស្តុកព្រៃឈើ

២. បង្ហាញឲ្យឃើញថា រេដបូកអាចជាវិធានការមួយក្នុងចំណោមវិធានការនានា ដើម្បីកម្ពុជាប្តូរទៅរកលំនាំនៃការអភិវឌ្ឍបៃតង

៣. លើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការចូលរួមនៅក្នុងសកម្មភាពកាត់បន្ថយការប្រែប្រួល អាកាសធាតុ ក្នុងវិស័យព្រៃឈើ

៤. បំពេញតាមលក្ខខណ្ឌសម្រាប់កម្ពុជានៅក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ដើម្បីអាចទទួលបានការទូទាត់ផ្អែកតាមលទ្ធផល សម្រាប់ការអនុវត្តគោលនយោបាយរេដបូក និងវិធានការនានា។

ដើម្បីសម្រេចចក្ខុវិស័យ បេសកកម្ម និងគោលបំណងទាំងនេះ យុទ្ធសាស្ត្ររេដបូកជាតិ បានកំណត់**គោលបំណងជាយុទ្ធសាស្ត្រ** ចំនួនបួន៖

១. កែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានព្រៃឈើ

២. លើកកម្ពស់ការប្រមូលផលព្រៃឈើប្រកបដោយនិរន្តភាព

៣. ពង្រឹងសមត្ថភាពដើម្បីត្រួតពិនិត្យតាមដានធនធានព្រៃឈើ

៤. បង្កើនសមត្ថភាព ចំណេះដឹង ការយល់ដឹង និងលើកកម្ពស់ការចូលរួមរបស់អ្នកពាក់ព័ន្ធ និងផល
ប្រយោជន៍។

ដោយអនុវត្តន៍តាមវិធីសាស្ត្រជាជំហានៗ យុទ្ធសាស្ត្ររេដបូកជាតិ បានចែកជាសកម្មភាពមួយចំនួន ដែលចែកចេញជាបីដំណាក់កាលសម្រាប់ការអនុវត្តដូចខាងក្រោម៖

**រយៈពេលខ្លីចំពោះមុខ (ឆ្នាំ២០១៦)៖** នៅក្នុងអំឡុងពេលនៃដំណាក់កាលនេះ ផែនការសកម្មភាព ពិស្តារ និងជាអាទិភាពសម្រាប់ឆ្នាំ ២០១៦-២០២០ នឹងត្រូវរៀបចំឡើង ដែលរួមទាំង ផែនការសកម្មភាពជាក់លាក់សម្រាប់ការអនុវត្តចំណេះដឹង និងមុខងារសម្របសម្រួលជាយុទ្ធសាស្ត្រ។ លើសពីនេះ ការរៀបចំស្ថាប័ន និងហិរញ្ញវត្ថុសម្រាប់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិក៏នឹងត្រូវរៀបចំឡើងផងដែរ រួមជាមួយការបង្កើតក្របខណ្ឌតាមដាន

DRAFT

និងវាយតម្លៃនៅថ្នាក់ជាតិ។

**រយៈពេលមធ្យម (ឆ្នាំ២០១៦-២០២០)៖** ការផ្តោតជាសំខាន់នៅក្នុងដំណាក់កាលនេះ គឺការអនុវត្តផែនការសកម្មភាព។ គោលបំណងចម្បងគឺធានាថា កម្ពុជានឹងអាចស្នើសុំឲ្យមានការទូទាត់ដោយផ្អែកតាមលទ្ធផល សម្រាប់សកម្មភាពរេដបូករបស់ខ្លួន។ ប្រការសំខាន់គឺ ត្រូវកត់សម្គាល់ថា សកម្មភាពនានាដែលបានអនុវត្តនៅក្នុងដំណាក់កាលនេះ ផ្តោតលើការដោះស្រាយទាំងបុព្វហេតុនៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ ប៉ុន្តែមានតែបណ្តាសកម្មភាពណាដែលបានដោះស្រាយបុព្វហេតុនៃបាត់បង់ព្រៃឈើប៉ុណ្ណោះ ដែលនឹងត្រូវបានវាយតម្លៃសម្រាប់ការទូទាត់ដោយផ្អែកតាមលទ្ធផល បើយោងតាមកម្រិតបច្ចេកទេស និងលទ្ធភាពនៃកម្រិតបំភាយយោងព្រៃឈើ កម្រិតយោងព្រៃឈើនៅក្នុងពេលបច្ចុប្បន្ននេះ។ សកម្មភាពដទៃទៀតត្រូវបានអនុវត្តន៍ដោយសារតែមូលហេតុចំនួនពីរដែលមានការទាក់ទងគ្នា៖ (១) ដើម្បីបង្កើតមេរៀនស្តីពីសកម្មភាពនានា សម្រាប់ដោះស្រាយបុព្វហេតុនៃការរេចរឹលព្រៃឈើ និងបុព្វហេតុដែលពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ការអភិរក្ស និងការបង្កើនកាបូនស្តុកព្រៃឈើ និង (២) មេរៀនទាំងនេះនឹងត្រូវយកទៅប្រើប្រាស់ជាកាលានុវត្តិភាពដើម្បីកែលម្អសមត្ថភាព និងកម្រិតបំភាយយោងព្រៃឈើកម្រិតយោងព្រៃឈើ ដែលមានបច្ចុប្បន្ន។

**រយៈពេលវែង (ក្រោយឆ្នាំ ២០២០/ដំណាក់កាល RBP)៖** នៅដើមឆ្នាំ២០២១ វិធីសាស្ត្រប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ កម្រិតបំភាយយោងព្រៃឈើ / កម្រិតយោងព្រៃឈើ និង ប្រព័ន្ធធានាសុវត្ថិភាព និងទិន្នន័យ នឹងត្រូវបានកែលម្អ ដូច្នេះ យុទ្ធសាស្ត្ររេដបូកជាតិនឹងត្រូវពង្រីក ដើម្បីរួមបញ្ចូលការអនុវត្តសកម្មភាពនានា ដែលដោះស្រាយបុព្វហេតុដទៃទៀតនៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ។ នៅទីបញ្ចប់ ប្រការសំខាន់គឺ ប្រសិទ្ធភាព ប្រសិទ្ធផល និងសមធម៌នៃគោលនយោបាយ និងវិធានការនានា ដើម្បីដោះស្រាយបុព្វហេតុនៃការបាត់បង់ព្រៃឈើរវាងឆ្នាំ២០១៦ - ២០២០ នឹងត្រូវបានតាមដាន យ៉ាងហ្មត់ចត់ តាមរយៈយន្តការផ្តល់យោបល់ឆ្លើយតបនៅក្នុងវិធីសាស្ត្រប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ និងប្រព័ន្ធធានាសុវត្ថិភាព ។ លើសពីនេះ វិធី សាស្ត្រ និងសកម្មភាពនានានៅតាមមូលដ្ឋានជាក់ស្តែង នឹងត្រូវកែលម្អជាបន្តបន្ទាប់ និងរៀបចំជាបន្ថែមទៅតាមការចាំបាច់ នៅពេលដែលទទួលបានការរៀនសូត្រ និងបទពិសោធន៍ពីការអនុវត្ត។

ការរៀបចំស្ថាប័នសម្រាប់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ទទួលស្គាល់ពីតួនាទីនិងការទទួលខុសត្រូវរបស់ស្ថាប័នផ្សេងគ្នានៅក្នុងរាជរដ្ឋាភិបាល ដែលមានសមត្ថកិច្ចលើធនធានព្រៃឈើនៅក្នុងប្រទេស។ ដូច្នេះ ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិត្រូវបានរំពឹងថានឹងគោរពទៅតាមដែនសមត្ថកិច្ចរបស់ស្ថាប័ននីមួយៗ នៃរាជរដ្ឋាភិបាលកម្ពុជា ដែលស្ថាប័ននីមួយៗនឹងរួមចំណែកក្នុងការរៀបចំផែនការសកម្មភាពរេដបូក សម្រាប់ដែនដីព្រៃឈើខុ



DRAFT

សៗគ្នា ដោយផ្អែកលើច្បាប់ និងគោលនយោបាយនានាដែលមានស្រាប់។ ដើម្បីត្រួតពិនិត្យការអនុវត្តយុទ្ធសាស្រ្តរេដបូកជាតិ គណៈកម្មាធិការរេដបូកជាតិនិងលេខាធិការដ្ឋានមួយនឹងត្រូវរៀបចំបង្កើតឡើងដើម្បី៖

១. ចាត់ចែងអនុវត្តអភិបាលកិច្ចនៅថ្នាក់ជាតិ និងសម្របសម្រួលរាល់សកម្មភាពរេដបូកនៅកម្ពុជា។

២. ត្រួតពិនិត្យ និងបង្កើនការកែលម្អអភិបាលកិច្ចធនធានព្រៃឈើ ដើម្បីកាត់បន្ថយអត្រានៃការបាត់បង់ ព្រៃឈើ និងការរេចរឹលព្រៃឈើ

៣. ធានាឲ្យមានសេវាប្រកបដោយប្រសិទ្ធភាពក្នុងការផ្តល់មូលនិធិ និងការវិភាជន៍បានត្រឹមត្រូវនូវការលើកទឹកចិត្តដល់ស្ថាប័ននានា ក្នុងការអនុវត្តសកម្មភាពរេដបូក។

DRAFT

## ១. សេចក្តីផ្តើម

### ១.១ រេដបូកនៅកម្រិតអន្តរជាតិ

ចាប់ពីឆ្នាំ ២០០៥មក ភាគីនានានៅក្រោមអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុបាន និងកំពុងធ្វើការចរចាយ៉ាងសកម្ម ដើម្បីបង្កើតកិច្ចផ្តួចផ្តើមគោលនយោបាយមួយ ដែលពាក់ព័ន្ធ ជាមួយការរៀបចំ និងការអនុវត្តសកម្មភាពនានា ដែលនឹងរួមចំណែកក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ តាមរយៈសកម្មភាពក្នុងវិស័យព្រៃឈើ។ កិច្ចផ្តួចផ្តើមនេះ ដែលត្រូវបានគេស្គាល់ថាជា **រេដបូក (REDD+)**ដែលមានន័យថា **កាត់បន្ថយការបំភាយពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ** និងបូក (+) តួនាទីនៃការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ការអភិរក្ស និងការបង្កើនកាបូនស្តុកព្រៃឈើនៅក្នុងប្រទេសកំពុងអភិវឌ្ឍ [១]។ តាមរយៈកិច្ចព្រមព្រៀងក្រុងខេនខូន នៅក្រោមអនុសញ្ញា UNFCCC ប្រទេសកំពុងអភិវឌ្ឍត្រូវបានលើកទឹកចិត្តឲ្យរួមចំណែកនៅក្នុងសកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុក្នុងវិស័យព្រៃឈើដោយអនុវត្តសកម្មភាពនានាដូចខាងក្រោម ទៅតាមករណី សមស្របសម្រាប់ភាគីនីមួយៗ និងអនុលោមតាមសមត្ថភាព និងកាលៈទេសៈរបស់ភាគីនីមួយៗទាំងនោះ រួមមាន៖

ក. កាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ព្រៃឈើ
ខ. កាត់បន្ថយការបំភាយឧស្ម័នពីការរេចរឹលព្រៃឈើ
គ. ការអភិរក្ស កាបូនស្តុកព្រៃឈើ
ឃ. ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព
ង. ការបង្កើនកាបូនស្តុកព្រៃឈើ

កិច្ចព្រមព្រៀងក្រុងខេនខូន ចែងបន្ថែមថា សកម្មភាពរេដបូក ត្រូវតែបានអនុវត្តជាដំណាក់កាល ដោយចាប់ផ្តើមពីការរៀបចំយុទ្ធសាស្ត្រជាតិ ឬ ផែនការសកម្មភាពរេដបូកជាតិ គោលនយោបាយ និងវិធានការនានា ព្រមទាំង ការកសាងសមត្ថភាព បន្តដោយការអនុវត្តគោលនយោបាយជាតិ និងវិធានការនានា និងយុទ្ធសាស្ត្រជាតិ ឬ ផែនការសកម្មភាពដែលអាចពាក់ព័ន្ធនឹងការកសាងសមត្ថភាពបន្ថែម ការអភិវឌ្ឍ និងការផ្ទេរបច្ចេកវិទ្យា និងសកម្មភាពអនុវត្តបង្ហាញដែលផ្អែកលើលទ្ធផល និងបន្ទាប់មកឈានទៅសកម្មភាពដែលផ្អែកលើលទ្ធផល ដែលអាចវាស់វែងបាន រាយការណ៍ និងផ្ទៀងផ្ទាត់បានដោយពេញលេញ[២]។

អនុសញ្ញា UNFCCC ក៏បានបង្កើតដំណើរការ វិធាននានា និងបែបបទសម្រាប់ប្រទេសកំពុងអភិ វឌ្ឍផងដែរ ដើម្បីទទួលបានការទូទាត់ផ្អែកលលទ្ធផល សម្រាប់សកម្មភាពរេដបូករបសខ្លួន។ ដោយឡែក នៅពេលថ្មីៗនេះ ក្របខ័ណ្ឌវ៉ស៊ែរសម្រាប់រេដបូក[១]

DRAFT

បានរំលឹកឡើងថា ប្រទេសកំពុងអភិវឌ្ឍដែលអនុវត្តសកម្មភាពនានាដូចមានយោងនៅក្នុងកិច្ចព្រមព្រៀងក្រុងខេនខូន អាចទទួលបានការទូទាត់ផ្អែកតាមលទ្ធផល(RBP) ចាំបាច់ត្រូវវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់(MRV)សកម្មភាពទាំងនោះដោយប្រុងប្រយ័ត្ន។ និយាយម្យ៉ាងទៀតថា ផ្អែកលើកិច្ចព្រមព្រៀងក្រុងខេនខូន ក្របខណ្ឌក្រុងវ៉ស៊រថៃងថា មុននឹងបានទទួលការទូទាត់ផ្អែកតាមលទ្ធផល ប្រទេសកំពុងអភិវឌ្ឍត្រូវមានធាតុផ្សំទាំងបួន ដែលបង្ហាញជូនក្នុងរូបទី ១ និងត្រូវផ្តល់តាមរយៈមណ្ឌលព័ត៌មានអនុសញ្ញា UNFCCC នូវសេចក្តីសង្ខេបថ្មីៗបំផុតអំពីរបៀបនៃការបង្កើត និងការគោរពតាមប្រព័ន្ធធានាសុវត្ថិភាពក្រុងខេនខូន។ នៅពេលដែលអ្វីៗទាំងនេះត្រូវបានបង្កើតរួចហើយ ប្រទេសកំពុងអភិវឌ្ឍណាមួយ អាចអនុវត្តតាមនីតិវិធីខុសៗគ្នាចំនួនពីរ ដើម្បីទទួលបានការទូទាត់ផ្អែកលើលទ្ធផល នៅក្រោមអនុសញ្ញា UNFCCC។ នីតិវិធីទីមួយគឺ ការវាយតម្លៃបច្ចេកទេសលើកម្រិតបំភាយយោងព្រៃឈើ / កម្រិតយោងព្រៃឈើ ដែលស្នើឡើង និងការត្រួតពិនិត្យ រាយការណ៍ និងការបញ្ជាក់នៃការបំភាយដែលទាក់ទងនឹងសកម្មភាពរបស់មនុស្សក្នុងវិស័យព្រៃឈើ ដោយគិតតាមប្រភព និងស្រូបកាបូនស្តុកព្រៃឈើ និងការប្រែប្រួលកាបូនស្តុកព្រៃឈើ និងទំហំដីព្រៃឈើតាមរយៈការអនុវត្តសកម្មភាពរេដបូក។ ផ្នែកទីពីរ គឺការធ្វើរបាយការណ៍លទ្ធផលនៃការកាត់បន្ថយតាមរយៈសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់នៅថ្នាក់ជាតិ និងឧបសម្ព័ន្ធបច្ចេកទេសមួយដែលជារបាយការណ៍បច្ចុប្បន្នភាពរយៈពេលពីរឆ្នាំម្តង (BUR)។

## ១.២ រេដបូកនៅកម្ពុជា

នៅក្នុងសន្និសីទភាគី (COP) ឆ្នាំ២០០៧ នៃអនុសញ្ញា UNFCCC ដែលបានធ្វើឡើងក្នុងប្រទេសឥណ្ឌូនេស៊ី មានការប្រកាសថា *"រាជរដ្ឋាភិបាលកម្ពុជាគាំទ្រយ៉ាងក្លៀវក្លាចំពោះការរួមបញ្ចូលការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីការអភិរក្សព្រៃឈើ និងការបញ្ជៀសការបាត់បង់ព្រៃឈើនៅក្នុងក្របខណ្ឌក្រោយអាណត្តិនៃពិធីសារក្យូតូ"*[១]។ កម្ពុជាបានធ្វើឲ្យមានវឌ្ឍនភាពយ៉ាងច្រើននៅក្នុងដំណាក់កាលត្រៀមលក្ខណៈ រេដបូករបស់ខ្លួន។ សូចនាករនៃវឌ្ឍនភាពនេះ[២] រួមមាន ការផលិតឯកសារបច្ចេកទេស និងការសិក្សានានាដូចខាងក្រោម ដែលផ្តល់ជាមូលដ្ឋានសម្រាប់កម្ពុជាបង្កើតសមាសភាគចំនួនបួន ដូចមានកំណត់ក្នុងក្របខណ្ឌ វ៉ស៊រសម្រាប់រេដបូក[៣] ពោលគឺយុទ្ធសាស្ត្ររេដបូកជាតិ ប្រព័ន្ធធានាសុវត្ថិភាព ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ និងកម្រិតបំភាយយោងព្រៃឈើ /កម្រិតយោងព្រៃឈើ:

- សេចក្តីព្រាងលើកទីបីនៃយុទ្ធសាស្ត្ររេដបូកជាតិកម្ពុជា (ឯកសារមានក្នុងវេបសាយ)
- ការវិភាគថ្លៃចំណាយ និងផលចំណេញពីការអនុវត្តរេដបូកនៅកម្ពុជា (ឯកសារមានក្នុងវេបសាយ)

DRAFT

- ប្រព័ន្ធចំណាត់ថ្នាក់គម្របដី និងព្រៃឈើកម្ពុជា (ឯកសារមាននៅក្នុងវេបសាយ)
- អនុសាសន៍ស្តីពីប្រព័ន្ធចំណាត់ថ្នាក់ដីធ្លី និងព្រៃឈើកម្ពុជា (ឯកសារមានក្នុងវេបសាយ)
- អនុសាសន៍ស្តីពីការរៀបចំសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ក្នុងបរិបទរេដបូកនៅកម្ពុជា (ឯកសារមានក្នុងវេបសាយ)
- កម្រងទិន្នន័យជារូបភាពពីផ្កាយរណប និងផែនទីសន្ទស្សន៍សម្រាប់ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិរបស់កម្ពុជា (ឯកសារមានក្នុងវេបសាយ)
- ការពិនិត្យជាបឋម និងវិធីសាស្ត្រនានាសម្រាប់បង្កើតប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពសម្រាប់រេដបូកនៅកម្ពុជា (ឯកសារមានក្នុងវេបសាយ)
- សមីការវិមាត្រសាស្ត្រ(អាឡូមេទ្រិក)រវាងមាឌដើមឈើ និងជីវម៉ាស់នៅកម្ពុជា (ឯកសារមានក្នុងវេបសាយ)
- ការបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងមូលនិធិប្រកបដោយតម្លាភាព និងគណនេយ្យភាពសម្រាប់រេដបូកនៅកម្ពុជា (ឯកសារមានក្នុងវេបសាយ)
- ការពិនិត្យជាបឋម និងវិធីសាស្ត្រដើម្បីបង្កើតប្រព័ន្ធសម្រាប់បែងចែកការលើកទឹកចិត្ត និងការចែកផលប្រយោជន៍សម្រាប់រេដបូកនៅកម្ពុជា (ឯកសារមានក្នុងវេបសាយ)
- ឆ្ពោះទៅបង្កើតប្រព័ន្ធបណ្តឹងសារទុក្ខរេដបូកនៅកម្ពុជា (ឯកសារមានក្នុងវេបសាយ)

ជារួម មកទល់ពេលនេះ សមាសភាគទាំងបួននៃក្របខ័ណ្ឌវ៉ស័រសម្រាប់រេដបូក កំពុងស្ថិតនៅក្នុងដំណាក់កាលខុសៗគ្នានៃការរៀបចំ។ គេមានការរំពឹងថា រហូតដល់ឆ្នាំ២០១៥ កម្ពុជានឹងបានបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ កម្រតិបំភាយយោងព្រៃឈើ / កម្រិតយោងព្រៃឈើនិងប្រព័ន្ធធានាសុវត្ថិភាព ជាទម្រង់ដំបូង។ លើសពីនេះ ជាមួយការគាំទ្រពីជនបង្គោលថ្នាក់ជាតិសម្រាប់រេដបូកនៅកម្ពុជា ក្រុមការងាររេដបូក និងស្ថាប័នពាក់ព័ន្ធលេខាធិការដ្ឋានក្រុមការងាររេដបូកនឹងសម្របសម្រួលឲ្យមានការអនុម័តគាំទ្រលើយុទ្ធសាស្ត្ររេដបូកជាតិដោយក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាពិសេស ដោយនាយករដ្ឋមន្ត្រី មុននឹងដាក់ជូននៅក្នុងសន្និសីទភាគីលើកទី២១ (COP21) នៃអនុសញ្ញា UNFCCC ដែលនឹងធ្វើឡើងនៅក្រុងប៉ារីស ក្នុងខែវិច្ឆិកា ឬខែធ្នូ ឆ្នាំ២០១៥។

ទីបំផុត នៅក្នុងទសវត្សរ៍ខាងមុខ គោលនយោបាយ ផែនការ កម្មវិធី និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនានារបស់កម្ពុជា នឹងបានរួមបញ្ចូលរេដបូក ជាផ្នែកមួយនៃរបៀបវារៈជាយុទ្ធសាស្ត្រ និងផែនការងាររបស់ ខ្លួន។ ឧទាហរណ៍ គោលដៅជាយុទ្ធសាស្ត្រទីបី នៃផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា (ឆ្នាំ ២០១៤-២០២៣) បានចាត់ទុករេដបូក ជាយន្តការមួយដើម្បីធានាថា ប្រព័ន្ធអេកូឡូស៊ីសំខាន់ៗមានភាពធន់ចំពោះអាកាសធាតុ។ នៅក្នុងឯកសារជាតិទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុករេដបូកជាមធ្យោបាយមួយរបស់កម្ពុ

ជា ក្នុងនាមជាហត្ថលេខីនៃអនុសញ្ញា UNFCCC ក្នុងការរួមចំណែកទៅក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុពិភពលោក ដែលអាចសម្រេចគោលបំណងចុងក្រោយនៃអនុសញ្ញា UNFCCC និងបំពេញបាននូវការប្តេជ្ញានានាក្រោមអនុសញ្ញានេះ។ ទន្ទឹមនឹងនេះ រេដបូកត្រូវបានចាត់ជាយន្តការដើម្បីកៀងគរការគាំទ្រហិរញ្ញវត្ថុបន្ថែមសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីរៀបចំគោលនយោបាយអភិវឌ្ឍន៍ជាតិដែលទាក់ទងនឹងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព និងការកាត់បន្ថយភាពក្រីក្រ ឬដើម្បីពង្រឹងការអនុវត្តគោលនយោបាយទាំងនេះ ១។[i]

DRAFT

## ២. ចក្ខុវិស័យ

កម្ពុជា រួមចំណែកក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ និងនៅកម្រិតពិភពលោក តាមរយៈការកែលម្អការគ្រប់គ្រងព្រៃឈើ ការអភិរក្សជីវចម្រុះ និងការអភិវឌ្ឍបៃតង។

## ៣. បេសកកម្ម

ការកែលម្អមុខងារ និងសមត្ថភាពរបស់ស្ថាប័នគ្រប់គ្រងព្រៃឈើ និងស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងការអនុវត្តគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិនានាដែលមានស្រាប់ ជាពិសេស ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍បៃតង និងរួមចំណែកក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

## ៤. គោលបំណង

១. កាត់បន្ថយការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ ទន្ទឹមនឹងលើកកម្ពស់ការអភិវឌ្ឍដោយ
 ចីរភាពការអភិរក្ស និងការបង្កើនកាបូនស្តុកព្រៃឈើ
២. បង្ហាញឲ្យឃើញថា រេដបូកអាចជាវិធានការមួយក្នុងចំណោមវិធានការនានា ដើម្បីកម្ពុជាប្តូរទៅរកលំនាំនៃការអភិវឌ្ឍបៃតង
៣. លើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការចូលរួមនៅក្នុងសកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុ នៅក្នុងវិស័យព្រៃឈើ
៤. បំពេញតាមលក្ខខណ្ឌសម្រាប់កម្ពុជានៅក្រោមអនុសញ្ញា UNFCCC ដើម្បីអាចទទួលបានការទូទាត់ផ្អែកតាមលទ្ធផល សម្រាប់ការអនុវត្តគោលនយោបាយរេដ និងវិធានការនានា។

## ៥. ក្របខណ្ឌយុទ្ធសាស្ត្រ

កម្ពុជាបានបង្កើតគោលនយោបាយ ច្បាប់ និងបទបញ្ញត្តិនានា ដើម្បីបន្សាំ និងដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ និងតាមវិស័យ/ក្រសួង។ យុទ្ធសាស្ត្ររេដបូកជាតិ របស់កម្ពុជា នឹងត្រូវបញ្ជ្រាបទៅក្នុងគោលនយោបាយទាំងនេះ ដោយផ្អែកលើគោលការណ៍ណែនាំសំខាន់ៗមួយចំនួន។

### ៥.១ គោលការណ៍ណែនាំ

១. ការរួមចំណែករបស់កម្ពុជាទៅក្នុងសមិទ្ធផលនៃគោលដៅនានាដូចមានចែងនៅក្នុង មាត្រា ២ និងការប្តេជ្ញានានា ដូចមានចែងក្នុងមាត្រា៤ វាក្យខណ្ឌ៣ នៃអនុសញ្ញា

DRAFT

UNFCCC

២. ផ្អែកលើយន្តការសម្របសម្រួលដែលមានស្រាប់របស់រាជរដ្ឋាភិបាលកម្ពុជា និងគាំទ្រដល់ការអនុវត្តគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិនានារបស់ជាតិ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍដោយចីរភាព

៣. ប្រឹងប្រែងផ្តល់ហិរញ្ញវត្ថុយ៉ាងច្រើន និងដែលអាចព្យាករណ៍បាន សម្រាប់ការអនុវត្ត និងពង្រីកយុទ្ធសាស្ត្រដែលមានស្រាប់សម្រាប់គ្រប់គ្រងព្រៃឈើ

៤. ធានាថាអ្នកពាក់ព័ន្ធនានាបានចូលរួមពេញលេញ និងប្រកបដោយប្រសិទ្ធភាព ដែលរួមទាំង អ្នកដែលងាយរងគ្រោះបំផុត ដូចជា សហគមន៍មូលដ្ឋាន ក្រុមជនជាតិដើម និងក្រុមស្ត្រី

៥. កសាងសមត្ថភាពនៅក្នុងស្ថាប័នរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធមិនមែនរដ្ឋាភិបាល

៦. មានសង្គតិភាពជាមួយដំណើរការនៃការចរចាជាអន្តរជាតិនៅក្រោមអនុសញ្ញា UNFCCC និងវិធីសាស្ត្រនានា ដែលបានបង្កើតឡើងដោយគណៈកម្មាធិការអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC)។

## ៥.២ ការវិភាគជាយុទ្ធសាស្ត្រ

### ការបន្សីជាមួយគោលបំណង និងអាទិភាពដទៃទៀតនៃការអភិវឌ្ឍជាតិ

ផែនទីបង្ហាញផ្លូវសម្រាប់ការត្រៀមលក្ខណៈរេដបូកនៅកម្ពុជា និងសមិទ្ធផលពីសកម្មភាពនានាដែលបានធ្វើឡើងនៅក្នុងពេលអនុវត្តផែនទីបង្ហាញផ្លូវ គឺជាមូលដ្ឋានសម្រាប់ការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ។ ផែនទីបង្ហាញផ្លូវនេះគឺជាផលិតផលមួយនៃការពិគ្រោះយោបល់ទូលំទូលាយ ជាមួយអ្នកពាក់ព័ន្ធខុសៗគ្នាពីថ្នាក់មូលដ្ឋាន រហូតដល់ថ្នាក់អន្តរជាតិ។ លើសពីនេះ ការរួមចំណែកទៅក្នុងយុទ្ធសាស្ត្រ និងកម្មវិធីនៃការគ្រប់គ្រងព្រៃឈើជាតិដែលមានបច្ចុប្បន្ន យុទ្ធសាស្ត្ររេដបូកជាតិ មានទាក់ទងគ្នាទៅនឹងគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីជាតិសម្រាប់អភិវឌ្ឍសេដ្ឋកិច្ចសង្គម និងបរិស្ថានដែលមានក្នុងពេលបច្ចុប្បន្ន។

ការយល់ឃើញថា យុទ្ធសាស្ត្ររេដបូកជាតិ គួរតែគាំទ្រ និងបំពេញបន្ថែមចំពោះការអនុវត្តផែនការអភិវឌ្ឍន៍ធំទូលាយទាំងនេះ និងមិនត្រូវបង្កើតផែនការ និងរចនាសម្ព័ន្ធគ្រប់គ្រងស្របគ្នា ឬប្រជែងគ្នាសម្រាប់ព្រៃឈើកម្ពុជាឡើយ។ ជាពិសេស ការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ ត្រូវពិចារណាគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីជាតិនានាដូចតទៅ៖

១. ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ (សេចក្តីព្រាងកំពុងស្ថិតក្នុងការរៀបចំ មានសេចក្តីដកស្រង់ខ្លះៗ)

២. ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០១៤-២០២៣

៣. យុទ្ធសាស្ត្រចតុកោណ ជំហានទី៣ ឆ្នាំ២០១៣-២០១៨
៤. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(NSDP) ឆ្នាំ២០១៤-២០១៨
៥. សូចនាករពិនិត្យតាមដានរួមគ្នា ឆ្នាំ២០១៤-២០១៨
៦. ផែនការសកម្មភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៤-២០១៨
៧. គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា
៨. គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍បៃតង ឆ្នាំ ២០១៣-២០៣០
៩.របាយការណ៍ជាតិលើកដំបូង និងសេចក្តីព្រាងរបាយការណ៍ជាតិលើកទី២ នៅក្រោមអនុសញ្ញា UNFCCC
១០. គោលនយោបាយ យុទ្ធសាស្រ្ត និងផែនការសកម្មភាពជាតិ និងតាមវិស័យ។

យុទ្ធសាស្ត្ររេដបូកជាតិ ត្រូវបានរៀបចំឡើងយ៉ាងទូលំទូលាយ និងមានតាមបែបផែននៃការចូលរួមពីអ្នកពាក់ព័ន្ធនៅកម្រិតខុសៗគ្នា។ អ្នកពាក់ព័ន្ធសំខាន់ៗត្រូវបានពិគ្រោះយោបល់នៅក្នុងការរៀបចំសេចក្តីព្រាងជំពូកខុសៗគ្នាដែលបង្កើតជាសេចក្តីព្រាងដំបូង និងសំណៅកែសម្រួលជាបន្តបន្ទាប់។ កម្ពុជាមានបំណងបង្ហាញជូនយុទ្ធសាស្ត្ររេដបូកជាតិ នៅក្នុង COP21 នៃអនុសញ្ញា UNFCCC ដែលត្រូវធ្វើឡើងនៅក្នុងក្រុងប៉ារីស នៅចុងឆ្នាំ២០១៥។ តារាងទី១ សង្ខេបដំណើរការពិគ្រោះយោបល់សម្រាប់ការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ ។ រូបទី ២ បង្ហាញពីយុទ្ធសាស្ត្ររេដបូកជាតិ នៅក្នុងគោលនយោបាយតាមវិស័យ និងគោលនយោបាយជាតិដែលមានស្រាប់។

## ទិដ្ឋភាពរួមនៃការគ្រប់គ្រងដីព្រៃនៅកម្ពុជា

កម្ពុជាមានផ្ទៃដីទំហំ១៨១.០៣៥គីឡូម៉ែត្រការ៉េ។ រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប៉ាន់ស្មានវិសាលភាពគម្របព្រៃឈើក្នុងឆ្នាំ២០១០ ប្រមាណ៥៧,៥៩%[ii] នៃផ្ទៃដីសរុបក្នុង ប្រទេស។ ព្រៃឈើនៅកម្ពុជាស្ថិតក្រោមដែនសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានរដ្ឋបាលព្រៃឈើ ជាស្ថាប័នទទួលខុសត្រូវនៃរដ្ឋាភិបាល។[iii] ក្រសួងបរិស្ថានទទួលខុសត្រូវលើតំបន់ការពារធម្មជាតិ ដែលរួមទាំងតំបន់ស្នូលនៃបបនីយជីវមណ្ឌលបឹងទន្លេសាប[iv] ចំណែករដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលខុសត្រូវលើព្រៃលិចទឹក និងព្រៃកោងកាង។[v] ភារកិច្ចទាំងនេះមានបង្ហាញក្នុងរូបទី៣។

កម្ពុជាបានឲ្យនិយមន័យព្រៃឈើដូចតទៅ៖ កន្សោមស្លឹកច្រើនជាង ១០% ផ្ទៃដីអប្បបរមា ០,៥ហ.ត និងដើមឈើមានកម្ពស់អប្បបរមា ៥ម។[vi] កម្ពុជាត្រូវបានចាត់ជាប្រទេស

ដែលមាន "អត្រាខ្ពស់នៃគម្របព្រៃឈើ និងអត្រាខ្ពស់នៃការបាត់បង់ព្រៃឈើ"។ នៅរវាងឆ្នាំ ១៩៩០ និងឆ្នាំ២០១០ រដ្ឋាភិបាលបានប៉ាន់ស្មានថា កម្ពុជាបានបាត់បង់ព្រៃឈើ ២២ភាគរយនៃគម្របព្រៃឈើរបស់ខ្លួន ឬត្រូវជាប្រមាណ២.៨៥០.០០០ហ.ត។ ការវាយតម្លៃគម្របព្រៃឈើជាតិ ដែលបានធ្វើឡើងនៅក្នុងឆ្នាំ ២០០៦ បានរកឃើញថា គម្របព្រៃឈើសរុបបានថយចុះពី៦១,២% នៅឆ្នាំ២០០២ មកត្រឹម៥៩,១% នៅឆ្នាំ ២០០៦ ដែលបង្ហាញពីការបាត់បង់ព្រៃឈើ ៣៧៣.៥១០ហ.ត ដោយសារតែការបម្លែងសម្រាប់គោលដៅផ្សេងៗ។[vii] រូបទី៤ បង្ហាញពីការប្រែប្រួលគម្របព្រៃឈើពីឆ្នាំ១៩៧៦ ដល់ឆ្នាំ២០០៦។

## បុព្វហេតុនៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើនៅកម្ពុជា

ការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ មានមូលហេតុជាច្រើន ដូច្នេះសកម្មភាពដើម្បីដោះស្រាយបុព្វហេតុទាំងនេះមានលក្ខណៈប្លែកៗគ្នា អាស្រ័យទៅតាមកាលៈទេសៈ សមត្ថភាព និងលទ្ធភាពរបស់ជាតិ។[viii] នៅកម្ពុជា កន្លែងភាគច្រើនដែលបានបាត់បង់ព្រៃឈើ គឺស្ថិតនៅក្នុងតំបន់ភ្នំ និងនៅតាមជួរភ្នំដែលមានព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោង។ ការប្រែប្រួលទាំងព្រៃស្រោង និងព្រៃល្បោះនៅតាមតំបន់ទំនាប ក៏ត្រូវបានសង្កេតឃើញថាកើតមាននៅក្នុងតំបន់វាលរាបផងដែរ។ លើសពីនេះ តំបន់សំខាន់ៗដែលមានការប្រែប្រួលព្រៃឈើច្រើនតែស្ថិតនៅក្នុងតំបន់ជាប់ព្រំដែនជាមួយប្រទេសឡាវ វៀតណាម និងថៃ។[ix] រូបទី៥ បង្ហាញពីកន្លែងសំខាន់ៗដែលមានការបាត់បង់ព្រៃឈើនៅកម្ពុជា រវាងឆ្នាំ១៩៨៨/៨៩ និង ២០០៥/២០០៦។ រូបទី៦ សង្ខេបពីការវាយតម្លៃគម្របព្រៃឈើសម្រាប់ឆ្នាំ២០០៩-២០១០។ រូបទី៧ បង្ហាញពីកន្លែងនានាដែលមានទិន្នន័យគម្របព្រៃឈើ និងសារពើភ័ណ្ឌព្រៃឈើ។ ស្ថានភាពនេះបង្ហាញពីការកន្លែងនានាដែលមានទិន្នន័យគម្របព្រៃឈើ និងសារពើភ័ណ្ឌព្រៃឈើ។ ស្ថានភាពនេះបង្ហាញពីការវាយតម្លៃខុសៗគ្នាអំពីគម្របព្រៃឈើ ដែលបានធ្វើឡើងនៅកម្រិតគម្រោង ដោយយោងទៅប្រព័ន្ធចំណាត់ថ្នាក់ព្រៃឈើខុសៗគ្នា។

ជារួម ការសិក្សាដែលបានធ្វើឡើងសម្រាប់ការរៀបចំសេចក្តីព្រាងផែនទីបង្ហាញផ្លូវរេដបូកកម្ពុជា បានរកឃើញថា ការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ បានកើតចេញពីដំណើរការដ៏សាំញ៉ាំ[x] ដែលរួមទាំង៖

- ការកែលម្អក្នុងដំណាក់កាលដំបូង នូវលទ្ធភាពចូលក្នុងតំបន់ព្រៃឈើដែលស្ថិតនៅទីកន្លែងឆ្ងាយដាច់ស្រយាល បានធ្វើឡើងតាមរយៈកំណើនយ៉ាងឆាប់រហ័សនៃសកម្មភាពកាប់ឈើជាលក្ខណៈពាណិជ្ជកម្មនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ដែលបានបញ្ឈប់នៅពេលដែលរដ្ឋាភិបាលបានប្រកាសផ្អាកការកាប់ឈើនៅក្នុងឆ្នាំ ២០០២ និងនៅក្នុងពេលថ្មីៗនេះ តាមរយៈគម្រោងសាងសង់ផ្លូវថ្នល់
- ភាពមិនប្រាកដប្រជានៃកម្មសិទ្ធិដីធ្លី ដែលលើកទឹកចិត្តឲ្យមានការចាប់យកដីធ្លី

ដោយផ្អែកលើសិទ្ធិក្នុងការតាំងទីលំនៅ សូម្បីល្មើសនឹងច្បាប់ភូមិបាលឆ្នាំ២០០១ ក៏ដោយ

- កង្វះខាតផ្នែកធនធានរបស់រដ្ឋាភិបាលនៅតាមតំបន់ដាច់ស្រយាល ក្នុងការគ្រប់គ្រងព្រៃឈើឲ្យមានប្រសិទ្ធភាព ដែលជាសម្បត្តិសាធារណៈរបស់រដ្ឋ នៅក្រោមច្បាប់ស្តីពីព្រៃឈើឆ្នាំ ២០០២ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ ២០០៨ និងច្បាប់ភូមិបាល ឆ្នាំ ២០០១
- កំណើនយ៉ាងឆាប់រហ័សនៃការពង្រីកកសិកម្ម និងសកម្មភាពអភិវឌ្ឍន៍ខ្នាតធំដទៃទៀត ដែលនាំឲ្យមានការរានឆ្ការជាទូទៅនៅតាមកន្លែងខ្លះៗ ដែលតាមធម្មតាតាមរយៈការប្រកាសសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច (ELCs និង SLCs)
- កំណើនតម្រូវការវត្ថុធាតុដើមនៅថ្នាក់តំបន់ និងពិភពលោក និង
- ភាពក្រីក្រនៅតាមជនបទ ដែលនៅតែមានជាទូទៅក្នុងប្រទេសកម្ពុជា។

កត្តានៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ ក៏កើតចេញពីប្រភពនៅក្រៅវិស័យព្រៃឈើផងដែរ។ កត្តាទាំងនេះរួមមាន ចំណូលស្រុកមកក្នុងតំបន់ព្រៃឈើ ការអភិវឌ្ឍកសិ-ឧស្សាហកម្ម ដូចជា សម្បទានដី ភាពទន់ខ្សោយនៃការអនុវត្តច្បាប់ភូមិបាល និងលិខិតបទដ្ឋានគតិយុត្តនានា ការលើកទឹកចិត្តខាងសេដ្ឋកិច្ច ដែលជំរុញឲ្យមានការរានឆ្ការព្រៃឈើ ភាពទន់ខ្សោយនៃបទប្បញ្ញត្តិស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងកង្វះការចុះបញ្ជីដីរដ្ឋ និងការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើ។[xi] តារាងទី ២ បង្ហាញពីកត្តានៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ ដែលបានកំណត់នៅក្នុងផែនទីបង្ហាញផ្លូវរេដបូកកម្ពុជា។

## កត្តាសំខាន់ៗដែលត្រូវដោះស្រាយតាមរយៈយុទ្ធសាស្ត្ររេដបូកជាតិ

យុទ្ធសាស្ត្ររេដបូកជាតិ នឹងមានប្រសិទ្ធភាព ប្រសិទ្ធផល និងសមធម៌ ក្នុងករណីដែល គោលបំណងយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រនានាត្រូវបានអនុវត្ត ដើម្បីដោះស្រាយកត្តានៃការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើ។ លទ្ធផលនៃការដោះស្រាយនឹងនាំឲ្យមានការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ការបង្កើនស្តុកកាបូនព្រៃឈើ និងការអភិរក្ស។ ដូចដែលបានបង្ហាញនៅផ្នែកខាងដើម កត្តានៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ មិនត្រឹមតែមានប្រភពខុសៗគ្នា និងស្ថិតនៅក្នុងដែនសមត្ថកិច្ចខុសគ្នាប៉ុណ្ណោះទេ វាក៏កើតឡើងទាំងនៅក្នុង និងនៅក្រៅវិស័យព្រៃឈើផងដែរ។ យុទ្ធសាស្ត្ររេដបូកជាតិអាចនឹងមិនសម្រេចបាន ក្នុងករណីយុទ្ធសាស្ត្រនេះ ប៉ុនប៉ងដោះស្រាយគ្រប់កត្តានៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ។ ។ ដូច្នេះ ដើម្បីកំណត់អត្តសញ្ញាណរីកត្តាសំខាន់ៗ ដែលគួរដោះស្រាយតាមរយៈការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិមានសកម្មភាពខុសៗគ្នាចំនួនបួនត្រូវបង្កើតឡើងរួមមាន៖ ។



DRAFT

សកម្មភាពទីមួយ ពាក់ព័ន្ធនឹងការពិនិត្យការសិក្សានានាកន្លងមកអំពីកត្តានៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ ជាពិសេស កត្តានានាដែលត្រូវបានប្រើប្រាស់ដើម្បីរៀបចំគោលនយោបាយជាតិដែលមានបច្ចុប្បន្ន ដូចជា កម្មវិធីព្រៃឈើជាតិ(NFP) សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិគ្រប់គ្រងតំបន់ការពារធម្មជាតិ(NPASMP) និងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល(SPFF)។ សកម្មភាពទីពីររួមមាន ការពិគ្រោះយោបល់ជាមួយអ្នកជំនាញការបច្ចេកទេសពាក់ព័ន្ធមកពីស្ថាប័នរដ្ឋាភិបាល និងស្ថាប័នមិនមែនរដ្ឋាភិបាលផ្នែកសង្គម នយោបាយ សេដ្ឋកិច្ច និងបច្ចេកវិទ្យា ដើម្បីដោះស្រាយកត្តានានាដែលបានរកឃើញ និងដើម្បីតាមដានលទ្ធផលតាមរយៈប្រព័ន្ធតាមដានព្រៃឈើជាតិ។ លទ្ធផល ទាំងអស់នេះត្រូវដាក់សម្រាប់ការពិភាក្សា ជាមួយមន្ត្រីជាន់ខ្ពស់ក្នុងរដ្ឋាភិបាលមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ដែលដឹកនាំកម្មវិធីរេដបូកជាតិ។ នៅទីចុងបញ្ចប់កិច្ចប្រជុំពិគ្រោះយោបល់នានាត្រូវបានចាត់ចែងឡើងជាមួយសមាជិកក្រុមការងាររេដបូក ក្រុមបច្ចេកទេស ក្រុមពិគ្រោះយោបល់ និងក្រុមយេនឌ័រ។

តាមរយៈដំណើរការពិគ្រោះយោបល់ទាំងនេះ តារាងខាងក្រោមបង្ហាញពីកត្តានៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ ដែលយុទ្ធសាស្ត្ររេដបូកជាតិ ប៉ុនប៉ងដោះស្រាយនៅក្នុងរយៈពេលប្រាំឆ្នាំខាងមុខ (២០១៦-២០២០)។ សេចក្តីសម្រេចនានាដើម្បីដោះស្រាយកត្តាដូចខាងក្រោមនេះ ត្រូវបានធ្វើឡើង ដោយពិចារណាផងដែរអំពី៖ ១) កម្រិតដែលអាចដោះស្រាយបាននៃកត្តាទាំងនោះ ២) សក្តានុពលក្នុងការកាត់បន្ថយការបំភាយឧស្ម័ន ៣) សមត្ថភាពបច្ចេកទេសក្នុងការតាមដាន រាយការណ៍ និងផ្ទៀងផ្ទាត់លទ្ធផលនានានៃយុទ្ធសាស្ត្រដែលបានបង្កើតឡើងដើម្បីដោះស្រាយកត្តានានាដែលបានជ្រើសរើសយក។

បន្ទាប់មក នៅពេលដែលមានការកែសម្រួលវិធីសាស្ត្រប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ និងទិន្នន័យ សកម្មភាពនានាដែលដោះស្រាយកត្តាដទៃទៀតនៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ ក៏នឹងត្រូវដាក់បញ្ចូលផងដែរ។ ជាការសំខាន់ណាស់ថាគោលនយោបាយ និងវិធានការនានា ដើម្បីដោះស្រាយកត្តាជាអាទិភាព រវាងឆ្នាំ២០១៦ និង២០២០ ត្រូវស្ថិតក្រោមការត្រួតពិនិត្យតាមដាន លើប្រសិទ្ធភាព ប្រសិទ្ធផល និងសមធម៌ តាមរយៈយន្តការទទួលយោបល់ឆ្លើយតបនៅក្នុង ប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិ និងប្រព័ន្ធព័ត៌មានធានាសុវត្ថិភាព។ លើសពីនេះ វិធីសាស្ត្រ និងសកម្មភាពនានានៅតាមទីវាល ជាក់ស្តែង ក៏ត្រូវតែរៀបចំ និងកែលម្អជាបន្តបន្ទាប់ ទៅតាមការចាំបាច់ ដូចជា បទពិសោធន៍ដែលអាចសម្រេចបានតាមវិធីសាស្ត្រជាជំហានៗ ការត្រួតពិនិត្យ ការទទួលយោបល់ឆ្លើយតប ការរៀនសូត្រ និងការសម្រាំងយុទ្ធសាស្ត្ររេដបូកជាតិ ។

| **ប្រភេទ** | **កត្តានានាដែលត្រូវដោះស្រាយរវាងឆ្នាំ ២០១៦-២០២០** |
|---|---|

| | |
|---|---|
| ផ្ទាល់ | ១. ការបម្លែងដីព្រៃឈើ<br>ក. ការអភិវឌ្ឍសេដ្ឋកិច្ច/កសិកម្ម (ដូចជា សម្បទានដីសេដ្ឋកិច្ច)<br>ខ. ការតាំងទីលំនៅ និងដីកសិកម្ម (ដូចជា សម្បទានដីសង្គមកិច្ច)<br>គ. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ (ដូចជា ការសាងសង់ផ្លូវថ្នល់ ទំនប់)<br>ឃ. ការធ្វើអាជីវកម្មរ៉ែ<br>២. ការទន្ទ្រានយកដីព្រៃឈើ<br>ក. ការជួញដូរដីធ្លី/ ការចាប់យកដីធ្លី<br>ខ. ការកាប់ឈើល្មើសច្បាប់<br>៣. ការប្រមូលផលពីព្រៃឈើដោយគ្មាននិរន្តភាព |
| ប្រយោល | - អភិបាលកិច្ចក្នុងវិស័យព្រៃឈើ និងវិស័យប្រើប្រាស់ដីនៅមានកម្រិត<br>- កង្វះការសម្របសម្រួលរវាងក្រសួងនានាលើការរៀបចំផែនការប្រើប្រាស់ដី<br>- ភាពក្រីក្រនៅជនបទ<br>- ការចូលរួមរបស់ក្រុមអ្នកពាក់ព័ន្ធនានានៅមានកម្រិត<br>- កង្វះហិរញ្ញវត្ថុ/ធនធានមនុស្សសម្រាប់រយៈពេលវែងដើម្បីគាំទ្រដល់វិស័យព្រៃឈើ<br>- ពុំមានទិន្នន័យ និងភស្តុតាងគ្រប់គ្រាន់សម្រាប់បង្កើតវិធានការទប់ស្កាត់ឧក្រិដ្ឋកម្មព្រៃឈើឲ្យមានប្រសិទ្ធភាព |

## ៥.៣ គោលបំណងយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រ

## គោលបំណងជាយុទ្ធសាស្ត្រ ១៖ កែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានព្រៃឈើ

**យុទ្ធសាស្ត្រ**

ក. លើកកម្ពស់ការរៀបចំផែនការតំបន់ទេសភាពព្រៃឈើឲ្យមានប្រសិទ្ធភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ខ. លើកកម្ពស់សន្តិសុខសុវត្ថិភាព ដីព្រៃឈើ និងការចាត់ថ្នាក់/ ការកំណត់តំបន់ព្រៃឈើ ការកំណត់ព្រំប្រទល់ព្រៃឈើ ការចុះបញ្ជិកាដីព្រៃឈើ ដែលអាស្រ័យលើ សារសំខាន់និងមុខងារ នៃប្រព័ន្ធអេកូឡូស៊ី (ដូចជា ការបង្កើតព្រៃការពារថ្មីៗ នៅក្នុងតំបន់ជីវចម្រុះសំខាន់ៗ)

គ. លើកកម្ពស់ការគ្រប់គ្រង និងប្រើប្រាស់ព្រៃឈើ និងដីព្រៃឲ្យមានប្រសិទ្ធភាព និងនិរន្តភាព

DRAFT

ឃ. កាត់បន្ថយផលប៉ះពាល់សង្គម និងបរិស្ថាន មកលើវិស័យព្រៃឈើ ពីប្រភពដែលកើតឡើងនៅក្នុង និងក្រៅវិស័យ

ង.បន្តការពន្យាផ្តល់សម្បទានដីសេដ្ឋកិច្ច និងពិនិត្យតាមដានស្ថានភាពសម្បទានសេដ្ឋកិច្ចដែលមានស្រាប់ដើម្បីពិនិត្យអនុលោមភាព និងពង្រឹងសមត្ថភាពតាមដានសម្បទានដីសេដ្ឋកិច្ច

ច.រួមចំណែកក្នុងការធ្វើសនិទានកម្ម (ការធានាថាគ្មានភាពត្រួតគ្នានៃតួនាទី និងការទទួលខុសត្រូវ) នៃក្របខ័ណ្ឌច្បាប់សម្រាប់ដីធ្លី និងធនធានព្រៃឈើ

ឆ.ពង្រឹងការគ្រប់គ្រងតំបន់អភិរក្សព្រៃឈើ (ព្រៃការពារ តំបន់ការពារធម្មជាតិ និងកន្លែងអភិរក្សជលផល)

## គោលបំណងជាយុទ្ធសាស្ត្រ ២៖ លើកកម្ពស់ការប្រមូលផលព្រៃឈើដោយនិរន្តភាព

### យុទ្ធសាស្ត្រ

ក.ពង្រឹង និងពង្រីកវិធីសាស្ត្រគ្រប់គ្រងព្រៃឈើដោយសហគមន៍ (ឧទាហរណ៍ សហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍នេសាទ)

ខ.លើកកម្ពស់ការប្រមូលផល និងការរៀបចំផែនការព្រៃឈើឲ្យមាននិរន្តភាព

គ.ពង្រឹងក្រមអនុវត្តក្នុងវិស័យព្រៃឈើ និងសកម្មភាពអភិបាលកិច្ច

ឃ. ដោះស្រាយតម្រូវការឈើ និងការផ្គត់ផ្គង់ថាមពលដែលមានប្រភពពីឈើ

ង.លើកកម្ពស់ខ្សែចង្វាក់ផ្គត់ផ្គង់ប្រកបដោយនិរន្តភាព ដែលផ្តល់ជម្រើសជំនួសការបាត់បង់ព្រៃឈើ (បង្កើនការចូលរួមរបស់វិស័យឯកជន)

ច.ដោះស្រាយផលប៉ះពាល់សង្គម និងបរិស្ថាន ដែលកើតចេញពីដំណើរការប្រមូលផលព្រៃឈើ

ឆ.លើកកម្ពស់ប្រភពផ្សេងនៃការផ្គត់ផ្គង់ឈើពីចម្ការឈើឯកជន

ជ.បង្កើនការដាំព្រៃឈើ/ការស្តារព្រៃឈើ និងការអនុវត្តរុក្ខវប្បកម្ម។

## គោលបំណងជាយុទ្ធសាស្ត្រ ៣៖ ពង្រឹងសមត្ថភាពដើម្បីពិនិត្យតាមដានធនធានព្រៃឈើ

### យុទ្ធសាស្ត្រ

ក.ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងសកម្មភាពអភិបាលកិច្ចព្រៃឈើ

ខ.ពង្រឹងសមត្ថភាព និងបច្ចេកទេសដើម្បីប្រមូល វិភាគ ធ្វើម៉ូដែល និងបកស្រាយទិន្នន័យព្រៃឈើ និងទិន្នន័យអំពីការប្រើប្រាស់ដី

គ.ពង្រីកប្រព័ន្ធសម្រាប់ការគ្រប់គ្រងទិន្នន័យ ការវិភាគទិន្នន័យ ការធានាគុណភាព/ការត្រួតពិនិត្យគុណភាព

## គោលបំណងជាយុទ្ធសាស្ត្រ ៥៖ បង្កើនសមត្ថភាព ចំណេះដឹង ការយល់ដឹង និងលើកកម្ពស់ការចូលរួមរបស់អ្នកពាក់ព័ន្ធ និងផលប្រយោជន៍សម្រាប់អ្នកពាក់ព័ន្ធ

**យុទ្ធសាស្ត្រ**

ក. ពង្រឹងស្ថាប័ន និងក្របខណ្ឌសម្របសម្រួលសម្រាប់ការរៀបចំផែនការប្រើប្រាស់ដីក្នុងគម្រោងអភិវឌ្ឍន៍/ហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ

ខ. កែលម្អសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់អនុវត្តគោលនយោបាយនានា ដើម្បីកាត់បន្ថយការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ

គ. ពង្រឹងយន្តការសម្របសម្រួលស្ថាប័ន ដើម្បីឆ្លើយតបដោយសង្គតិភាពខាងគោលនយោបាយសម្រាប់ដោះស្រាយបញ្ហាបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ

ឃ. លើកកម្ពស់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ដើម្បីបង្កើនហិរញ្ញវត្ថុបន្ថែមសម្រាប់គាំទ្រដល់វិស័យព្រៃឈើ

ង. បញ្ជ្រាបគោលនយោបាយ និងវិធានការរេដបូក ជាមួយគោលនយោបាយជាតិ និងវិស័យពាក់ព័ន្ធ

ច. ពង្រឹងតួនាទីរបស់គ្រឹះស្ថានសិក្សា/វិទ្យាស្ថានស្រាវជ្រាវ ក្នុងការបណ្តុះបណ្តាល ការស្រាវជ្រាវ និងការអភិវឌ្ឍបច្ចេកវិទ្យាស្តីពីគោលនយោបាយព្រៃឈើ និងការប្រើប្រាស់ដី

ឆ. លើកទឹកចិត្ត ការចូលរួមជាសារធារណៈ និងការពិគ្រោះយោបល់ជាសាធារណៈ ដែលជាចំណុចចាប់ផ្តើមបឋមសម្រាប់ការរៀបចំផែនការវិស័យព្រៃឈើ និងការប្រើប្រាស់ដី ការលើកកម្ពស់ការចូលរួមរបស់អ្នកពាក់ព័ន្ធនានា ដែលរួមទាំង អង្គការមិនមែនរដ្ឋាភិបាល សហគមន៍មូលដ្ឋាន ក្រុមជនជាតិដើម យុវជន និងវិស័យឯកជន

ជ. គាំទ្រដល់កម្មវិធីអភិវឌ្ឍន៍មុខរបរចិញ្ចឹមជីវិត ដើម្បីបង្កើនអត្ថប្រយោជន៍ច្រើនមុខ។

## ៦. សកម្មភាព

យុទ្ធសាស្ត្ររេដបូកជាតិ ផ្តល់ក្របខណ្ឌធំទូលាយមួយសម្រាប់ការអនុវត្តសកម្មភាពរេដបូកនៅកម្ពុជា។ កម្ពុជានៅត្រូវការរៀបចំផែនការសកម្មភាពរេដបូកមួយ និងយន្តការក្របខ័ណ្ឌអនុវត្តដែលពាក់ព័ន្ធនានា ដូចជាយន្តការហិរញ្ញប្បទាន ក្របខណ្ឌតាមដាននិងវាយតម្លៃ និងក្របខណ្ឌច្បាប់សម្រាប់អនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ និងដើម្បីផ្តល់ជាមូលដ្ឋានគ្រឹះដ៏រឹងមាំមួយសម្រាប់ការគៀងគរធនធាន។

### ៦.១ ដំណាក់កាលនានាសម្រាប់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ

ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ នឹងធ្វើឡើងតាមវិធីសាស្ត្រជាជំហានៗ ដូចខាង

ក្រោម៖

## នៅរយៈពេលខ្លីចំពោះមុខ (ឆ្នាំ ២០១៦)៖ ការរៀបចំផែនការសកម្មភាពរេដបូក

នៅក្នុងអំឡុងពេលនៃដំណាក់កាលនេះ ផែនការសកម្មភាពពិស្តារ និងជាអាទិភាពមួយសម្រាប់ឆ្នាំ ២០១៦-២០២០ នឹងត្រូវរៀបចំឡើង ដែលរួមទាំងផែនការសកម្មភាពជាក់លាក់ សម្រាប់ការគ្រប់គ្រងចំណេះដឹងជាយុទ្ធសាស្ត្រ និងសម្រាប់សម្របសម្រួល។ លើសពីនេះ ការចាត់ចែងស្ថាប័ន និងហិរញ្ញវត្ថុសម្រាប់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ក៏នឹងត្រូវធ្វើឡើងផងដែរ រួមជាមួយការបង្កើតក្របខណ្ឌជាតិសម្រាប់ការតាមដាននិងវាយតម្លៃ។ សកម្មភាពដទៃទៀតដែលត្រូវសម្រេចឲ្យបាន រួមមាន៖

១. សំណើសម្រាប់ការរៀបចំប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិរបស់កម្ពុជា សម្រាប់ប្រព័ន្ធត្រួតពិនិត្យ រាយការណ៍ និងការបញ្ជាក់ នៅថ្នាក់ជាតិ
២. សំណើដើម្បីរៀបចំកម្រិតបំភាយយោងព្រៃឈើ / កម្រិតយោងព្រៃឈើ សម្រាប់កម្ពុជា
៣. ការរៀបចំ និងការសាកល្បងអនុវត្តជាដំបូងនូវប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ ប្រព័ន្ធធានាសុវត្ថិភាព និងកម្រិតបំភាយយោងព្រៃឈើ / កម្រិតយោងព្រៃឈើ

## នៅក្នុងរយៈពេលមធ្យម (ឆ្នាំ ២០១៦-២០២០)៖ ការអនុវត្តផែនការសកម្មភាពរេដបូក

នៅក្នុងវិស័យព្រៃឈើ កត្តាជាអាទិភាពដែលត្រូវដោះស្រាយនៅក្នុងរយៈពេលប្រាំឆ្នាំខាងមុខច្រើនតែអាចសម្រេចបាន តាមរយៈការពង្រឹងការអនុវត្តកម្មវិធីគ្រប់គ្រងព្រៃឈើដែលមានស្រាប់របស់កម្ពុជា ដូចជា កម្មវិធីព្រៃឈើជាតិ ផែនការគ្រប់គ្រងយុទ្ធសាស្ត្រតំបន់ការពារធម្មជាតិ ក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់ជលផល និងអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច និងសង្គមកិច្ច ។ ឯកសារទាំងនេះ ក៏រួមបញ្ចូលសកម្មភាពនានា ដូចជា ការអនុវត្តច្បាប់ កំណែទម្រង់កម្មសិទ្ធិដីព្រៃ និងសហគ្រប់គ្រងការប្រើប្រាស់ដីព្រៃផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តកម្មវិធី និងសកម្មភាពនានាដូចមានចែងនៅក្នុងឯកសារទាំងនេះ ត្រូវរាំងស្ទះដោយសារខ្វះហិរញ្ញវត្ថុ និងសមត្ថភាពបច្ចេកទេស។ គេអាចជម្នះឧបសគ្គខាងហិរញ្ញវត្ថុ និងសមត្ថភាពបច្ចេកទេសទាំងនេះបាន តាមរយៈការគាំទ្រដែលត្រូវទទួលបាននៅក្រោមប្រព័ន្ធទូទាត់ផ្អែកលើលទ្ធផល សម្រាប់សកម្មភាពរេដបូក។ លើសពីនេះ ដោយហេតុថា កត្តាជាអាទិភាពទាំងនេះមានទំនាក់ទំនងជិតស្និទ្ធ និងស្ថិតក្រោមឥទ្ធិពលនៃកត្តាធំៗផ្សេងទៀត ដូចជា អភិបាលកិច្ចធនធានធម្មជាតិ កំណើនចំនួនប្រជាជន និងសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ច យុទ្ធសាស្ត្រជាតិរេដបូក ក៏ត្រូវតែផ្តោតលើការអនុវត្តសកម្មភាព នៅក្រៅវិស័យព្រៃឈើផងដែរ។

ទាក់ទងនឹងលក្ខខណ្ឌបច្ចេកទេសដើម្បីកម្ពុជាត្រៀមខ្លួនសម្រាប់ការទូទាត់ផ្អែកលើលទ្ធផលនៅក្រោមយន្តការរេដបូក រហូតដល់ឆ្នាំ ២០២០ កម្ពុជាគួរតែមានប្រព័ន្ធតាមដាន



DRAFT

ត្រួតពិនិត្យព្រៃឈើជាតិ កម្រិតបំភាយយោង និង ប្រព័ន្ធព័ត៌ធានាសុវត្ថិភាព ដែលអាចដំណើរការបានពេញលេញ ដែលអាចគណនាបរិមាណនៃការបំភាយដែលបានកាត់បន្ថយតាមរយៈការអនុវត្តសកម្មភាពនានា ដែលមានកំណត់នៅក្នុងផែនការសកម្មភាពរេដបូក ទន្ទឹមនឹងការធានាថា បានដោះស្រាយ និងគោរពលក្ខខណ្ឌប្រព័ន្ធធានាសុវត្ថិភាពក្រុងកាន់គុនផងដែរ។

ដើម្បីធ្វើបែបនេះបាន សកម្មភាពដូចតទៅ នឹងត្រូវតែបានដាក់ឲ្យអនុវត្តនៅមុនឆ្នាំ ២០២០៖

១. រៀបចំគោលនយោបាយ ស្តង់ដារ និងយន្តការនានាដែលទាក់ទងនឹងសកម្មភាពការវាស់វែង ត្រួតពិនិត្យ រាយការណ៍ និងការបញ្ជាក់ ដោយមានការអនុម័តពីក្រុមការងាររេដបូក។ ឯកសារ និងយន្តការនានាទាំងនេះ រួមបញ្ចូល ការសម្របសម្រួលស្ថាប័ន និងការចែករំលែកទិន្នន័យ ការធ្វើសុខុដុម្មនីយកម្មទិន្នន័យ ការធានាគុណភាព និងវិធានការត្រួតពិនិត្យ ការផ្តល់សុពលភាពលើការគណនាបរិមាណឧស្ម័នផ្ទះកញ្ចក់ ដែលបានធ្វើឡើងនៅលំដាប់ថ្នាក់ខុសៗគ្នា ដែលរាប់ចាប់ពីទីតាំងនីមួយៗនៅតាមមូលដ្ឋាន រហូតដល់ថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។ ប្រព័ន្ធនេះនឹងត្រូវរៀបចំឡើង ស្របជាមួយសេចក្តីសម្រេចរបស់អនុសញ្ញា UNFCCC និងគោលការណ៍ណែនាំរបស់ IPCC។

២. ប្រមូលផ្តុំព័ត៌មានពីសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់នៅកម្រិតជាតិ សម្រាប់វិស័យព្រៃឈើ និងការប្រើប្រាស់ដីនៅកម្ពុជា ដើម្បីគណនាឥទ្ធិពលពីការកាត់បន្ថយ ដែលកើតចេញពីការអនុវត្តសកម្មភាពរេដបូកនៅកម្រិតជាតិ។ សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ ត្រូវរួមបញ្ចូល ការបំភាយ និងការដកហូត ដែលពាក់ព័ន្ធទាំងអស់ នៅក្នុងព្រំដែននៃប្រទេស។

៣. បង្កើតយន្តការចែកចាយព័ត៌មាន សម្រាប់ការគ្រប់គ្រង និងរៀបចំទិន្នន័យភូមិសាស្ត្រ និងទិន្នន័យ ដទៃទៀត សម្រាប់អ្នកពាក់ព័ន្ធនានាយកទៅប្រើប្រាស់។

៤. ចាត់ចែងឲ្យមានភាពបំពេញគ្នារវាងប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិជាមួយប្រព័ន្ធព័ត៌មានសម្រាប់សុវត្ថិភាពរេដបូក។

៥. នៅក្នុងប្រតិបត្តិការប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិត្រូវធានាឲ្យមានទិន្នន័យសុក្រឹតអំពីការប្រែប្រួលនៃការប្រើប្រាស់ដីព្រៃនិងផលប៉ះពាល់មកលើស្តុកកាបូន និងមុខងារផ្សេងទៀតនៃប្រព័ន្ធអេកូឡូស៊ី។

៦. ប្រមូលផ្តុំទិន្នន័យពាក់ព័ន្ធ និងរាយការណ៍ពីលទ្ធផលនានាដែលបានពីការអនុវត្តរេដបូក ទៅលេខាធិការដ្ឋានអនុសញ្ញា UNFCCC តាមរយៈឧបសម្ព័ន្ធបច្ចេកទេសមួយភ្ជាប់ជាមួយរបាយការណ៍បច្ចុប្បន្នភាពប្រចាំពីរឆ្នាំម្តងរបស់កម្ពុជា (BUR)។

៧. កសាងសមត្ថភាពសម្របសម្រួលក្នុងចំណោមអ្នកអនុវត្តប្រព័ន្ធតាមដានត្រួតពិនិត្

យព្រៃឈើជាតិ ប្រព័ន្ធព័ត៌មានសុវត្ថិភាព និងការវាស់វែង ត្រួតពិនិត្យ រាយការណ៍ និងការបញ្ជាក់ នៅក្នុងស្ថាប័នរេដបូកដែលពាក់ព័ន្ធ។

## នៅក្នុងរយៈពេលវែង(ក្រោយឆ្នាំ ២០២០)៖ ដំណាក់កាលនៃការទូទាត់ដោយផ្អែកលើលទ្ធផល

ដោយគោរពទៅតាមគោលការណ៍នៃការអនុវត្តជាជំហានៗ ដូចដែលបានកត់សំគាល់ពីខាងដើម នៅដើមឆ្នាំ ២០២១ ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ ប្រព័ន្ធធានាសុវត្ថិភាព និងការវាស់វែង ត្រួតពិនិត្យ រាយការណ៍ និងការបញ្ជាក់និងទិន្នន័យនានា នឹងត្រូវបានកែលម្អរួចទៅហើយ ដូច្នេះយុទ្ធសាស្ត្រជាតិរេដបូក នឹងអាចពង្រីក ដើម្បីរួមបញ្ចូលការអនុវត្តសកម្មភាពនានា ដែលដោះស្រាយកត្តានានាដទៃទៀតនៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ។ នៅក្នុងរយៈពេលមួយឆ្នាំមុនចុងបញ្ចប់នៃដំណាក់កាលអនុវត្ត គេត្រូវធ្វើការវាយតម្លៃដោយឯករាជ្យ និងពេញលេញ អំពីភាពខ្លាំង ភាពទន់ខ្សោយ ឱកាស និងការគំរាមកំហែងសម្រាប់យុទ្ធសាស្ត្រជាតិរេដបូក ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ ប្រព័ន្ធធានាសុវត្ថិភាព និងការវាស់វែង ត្រួតពិនិត្យ រាយការណ៍ និងការបញ្ជាក់ ។ ទន្ទឹមនឹងនេះ ការពិគ្រោះយោបល់ពេញលេញ និងដោយប្រសិទ្ធភាព ជាមួយអ្នកពាក់ព័ន្ធនានាមកពីស្ថាប័នរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ជាពិសេស អ្នកទាំងអស់ដែលតំណាងឲ្យសហគមន៍មូលដ្ឋាន ក្រុមជនជាតិដើម និងក្រុមស្ត្រី អំពីកត្តាបន្ថែម និងសកម្មភាពនានា ដើម្បីអនុវត្តនៅក្នុងដំណាក់កាលទីពីរនៃយុទ្ធសាស្ត្ររេដបូកជាតិ គឺជាការចាំបាច់។

លើសពីនេះ គេចាំបាច់ត្រូវធ្វើការសិក្សាបន្ថែមទៀតអំពីកត្តានានានៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ ការគណនាកត្តាទាំងនេះ ដោយគិតជាបរិមាណនៃការបំភាយកាបូន ការចាត់កត្តាសំខាន់ៗជាអាទិភាព ដើម្បីដោះស្រាយនៅក្រោយឆ្នាំ ២០២០ និងការគិតគូរអំពីឱកាស និងឧបសគ្គខាងនយោបាយ សង្គម សេដ្ឋកិច្ច និងបច្ចេកវិទ្យា ដើម្បីដោះស្រាយកត្តានានាទាំងនេះ នៅក្នុងបរិបទ និងកម្រិតសមត្ថភាពរបស់ជាតិ។ ក្រៅពីនេះ ដើម្បីធានាអនុលោមភាពជាមួយសេចក្តីសម្រេចនានាជាអន្តរជាតិស្តីពីរេដបូក គេត្រូវធ្វើការសិក្សាឯកសារនានាដែលមានស្រាប់អំពី គោលនយោបាយ សេចក្តីសម្រេច គោលការណ៍ណែនាំពីស្ថាប័ននានា ដូចជា UNFCCC និង IPCC រវាងឆ្នាំ ២០១៦ និង ២០២០។ នៅទីបំផុត ប្រការសំខាន់គឺត្រូវពិនិត្យតាមដានប្រសិទ្ធភាព ប្រសិទ្ធផល និងសមធម៌ នៃគោលនយោបាយ និងវិធានការនានា ដើម្បីដោះស្រាយកត្តានៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើនៅរវាងឆ្នាំ ២០១៦ និង ២០២០ តាមរយៈយន្តការទទួលយោបល់ឆ្លើយតបនៅក្នុងប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិ និងប្រព័ន្ធព័ត៌មានសុវត្ថិភាព ។ វិធី និងសកម្មភាពនានានៅតាមមូលដ្ឋាន ត្រូវបានបន្តកែលម្អ និងអភិវឌ្ឍន៍ជាបន្ថែមទៀត ទៅតាមការចាំបាច់ ក្រោយ

បានរៀនសូត្រពីបទពិសោធន៍ល្អៗ។

### ៦.២ ក្របខណ្ឌវ៉ស័រ(Warsaw)សម្រាប់រេដបូក

ដើម្បីអាចស្នើសុំការទូទាត់ដោយផ្អែកលើលទ្ធផលសម្រាប់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ កម្ពុជាត្រូវមានធាតុផ្សំផ្សេងទៀត ចំនួនបីដែលត្រូវអនុម័តជាផ្នែកមួយនៃក្របខណ្ឌក្រុងវ៉ស័រ។ ផ្នែកនានាខាងក្រោមនេះបង្ហាញពីស្ថានភាពបច្ចុប្បន្ន និងផែនការអនាគតសម្រាប់ធាតុផ្សំទាំងបីនៃក្របខណ្ឌក្រុងវ៉ស័រ។

### ៦.២.១ ប្រព័ន្ធធានាសុវត្ថិភាព (SIS)

យោងតាមសេចក្តីសម្រេចនៃសន្និសីទ COP នៃអនុសញ្ញា UNFCCC ដើម្បីឲ្យប្រទេសនានាអាចទទួលបានការទូទាត់ដោយផ្អែកលើលទ្ធផល ប្រទេសទាំងនោះត្រូវបង្កើតវិធីសាស្ត្រជាតិសម្រាប់ប្រព័ន្ធសុវត្ថិភាព ដើម្បីលើកកម្ពស់ និងគាំទ្រដល់ប្រព័ន្ធសុវត្ថិភាពទាំងប្រាំពីរនៃក្រុងកាន់គុន និងដើម្បីបង្កើតប្រព័ន្ធធានាសុវត្ថិភាព សម្រាប់ផ្តល់សេចក្តីសង្ខេបព័ត៌មានអំពីរបៀបឆ្លើយតប និងការគោរពតាមប្រព័ន្ធសុវត្ថិភាពក្រុងកាន់គុន នៅក្រោមសកម្មភាពរេដបូក។ ការឆ្លើយតបបានតាមលក្ខខណ្ឌទាំងនេះ មិនត្រឹមតែអាចឲ្យប្រទេសនានាទទួលបានការទូទាត់ផ្អែកលើលទ្ធផលប៉ុណ្ណោះទេ ប៉ុន្តែក៏ជាមធ្យោបាយដ៏សំខាន់ដើម្បីកែលម្អតម្លាភាព និងគណនេយ្យភាពនៅក្នុងការអនុវត្តរេដបូកផងដែរ។ ប្រការនេះអាចបង្កើនឱកាសរបស់ប្រទេសណាមួយ ក្នុងការទាក់ទាញហិរញ្ញវត្ថុ(ការវិនិយោគ)ជាមុនសម្រាប់ការអនុវត្តគោលនយោបាយ និងវិធានការរេដបូក។

## ស្ថានភាពនៃសកម្មភាព

## ១. ការបង្កើតវិធីសាស្ត្រជាតិសម្រាប់ប្រព័ន្ធសុវត្ថិភាពក្រុងកាន់គុន

**គោលការណ៍ និងលក្ខណៈវិនិច្ឆ័យសម្រាប់ប្រព័ន្ធសុវត្ថិភាពរេដបូកនៅកម្ពុជា៖** រាជរដ្ឋាភិបាលកម្ពុជា ប្រឹងប្រែងបង្កើតគោលការណ៍សុវត្ថិភាព និងលក្ខណៈវិនិច្ឆ័យ ដោយរួមបញ្ចូលឲ្យបានពេញលេញនូវទស្សនវិស័យរបស់អ្នកពាក់ព័ន្ធទៅក្នុងវិធីសាស្ត្រនេះ ទន្ទឹមនឹងកំហិតលើចំនួនគោលការណ៍ និងលក្ខណៈវិនិច្ឆ័យ ដើម្បីធ្វើឲ្យការពិនិត្យតាមដាន និងការធ្វើរបាយការណ៍មានលក្ខណៈជាក់ស្តែង និងអាចសម្រេចបាន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ចែងការប្រជុំពិគ្រោះយោបល់នៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ជាមួយអ្នកពាក់ព័ន្ធសរុបចំនួន ៣១៧នាក់ មកពីស្ថាប័ន និងគ្រឹះស្ថានរដ្ឋាភិបាលដែលពាក់ព័ន្ធ អង្គការសង្គមស៊ីវិល សហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើម។ ការពិគ្រោះយោបល់ទូលំទូលាយទាំងនេះ បាននាំឲ្យមានការរៀបចំសំណើចុងក្រោយមួយដែលមានគោលការណ៍ចំនួន ៧ចំណុច និងលក្ខណៈវិនិច្ឆ័យចំនួន ១៩ សម្រាប់កម្ពុជា ដែលបានផ្អែកជាសំខាន់លើ

ប្រព័ន្ធសុវត្ថិភាពទាំងប្រាំពីរនៃក្រុងកាន់គុន ដោយរួមបញ្ចូលពាក្យ“ស្ត្រី” និង “ព្រៃដាំ” ទៅក្នុងចំណុច (ង) និង (ច) នៃប្រព័ន្ធសុវត្ថិភាពក្រុងកាន់គុន និងលក្ខណៈវិនិច្ឆ័យបន្ថែមដើម្បីដោះស្រាយកង្វល់របស់អ្នកពាក់ព័ន្ធឲ្យបានពេញលេញ។

**ការវិភាគភាពខ្វះចន្លោះក្នុងគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិនានា៖** ស្របជាមួយដំណើរការពិគ្រោះយោបល់ទាំងនេះ ការវិភាគដំបូងមួយត្រូវបានធ្វើឡើង ដើម្បីកំណត់រកភាពខ្វះចន្លោះដែលអាចមានរវាងគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិនានាដែលមានស្រាប់នៅកម្ពុជា និងសំណើគោលការណ៍សុវត្ថិ-ភាព និងលក្ខណៈវិនិច្ឆ័យសម្រាប់កម្ពុជា។ ការងារនេះឆ្លើយតបនឹងការសម្រេចរបស់អនុសញ្ញា UNFCCC ដែលថាប្រទេសនានាគួរផ្តល់សេចក្តីសង្ខេបព័ត៌មានអំពីរបៀប”ដោះស្រាយ”ប្រព័ន្ធសុវត្ថិភាពក្រុងកាន់គុន។ ការវិភាគភាពខ្វះចន្លោះនេះបានសន្និដ្ឋានថា រាជរដ្ឋាភិបាលកម្ពុជា មានលិខិតបទដ្ឋាន គោលនយោបាយ និងច្បាប់ មួយចំនួន ដែលអាច”ដោះស្រាយ”គោលការណ៍ និងលក្ខណៈវិនិច្ឆ័យនៃសំណើប្រព័ន្ធធានាសុវត្ថិភាព ជាពិសេស សម្រាប់ប្រព័ន្ធសុវត្ថិភាពសង្គម។ ការវិភាគនេះក៏បានកំណត់រកឃើញតម្រូវការ ដើម្បីគិតគូរអំពីប្រព័ន្ធសុវត្ថិភាពបរិស្ថានបន្ថែមទៀត ដើម្បីដោះស្រាយហានិភ័យនៃការវិលត្រឡប់មកស្ថានភាពដើមវិញ និងការបម្លាស់ទីផងដែរ។

## ២. សំណើសូចនាករដំបូង និងប្រភពទិន្នន័យសម្រាប់ប្រព័ន្ធធានាសុវត្ថិភាពរបស់កម្ពុជា

កម្ពុជាបានស្នើឲ្យមានសូចនាករដំបូងមួយឈុត និងប្រភពទិន្នន័យសម្រាប់តាមដាន និងរាយការណ៍ អំពីថាតើប្រព័ន្ធធានាសុវត្ថិភាពត្រូវបានដោះស្រាយ និងគោរពតាមបានដោយរបៀបណា នៅទូទាំងការអនុវត្តយុទ្ធសាស្ត្រជាតិរេដបូក។ គេត្រូវធ្វើកិច្ចការនេះបន្ថែមទៀត ដើម្បីវាយតម្លៃអំពីប្រភេទព័ត៌មាន ដែលត្រូវប្រមូលយក និងការវិភាគ សម្រាប់សូចនាករនីមួយៗ និងលទ្ធភាពនៃការទទួលបានព័ត៌មានទាំងនោះ (សូមអានជំហាននានាដូចខាងក្រោម)។

### ការប្រឈម/ឧបសគ្គនានា

ទោះបីសម្រេចបានលទ្ធផលដូចខាងលើហើយក៏ដោយ ការប្រឈមនិងឧបសគ្គនានានៅតែមាននៅឡើយ៖

- កង្វះសេចក្តីសម្រេចអំពីយុទ្ធសាស្ត្រជាក់លាក់ ដើម្បីដោះស្រាយកត្តានៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ និងឧបសគ្គនានាចំពោះសកម្មភាព ‘+’ ដែលជាឧបសគ្គចំពោះការរៀបចំប្រព័ន្ធធានាសុវត្ថិភាព
- កង្វះការពិនិត្យមើលច្បាប់ និងបច្ចេកទេសនានាអំពីសំណើលិខិតបទដ្ឋាន គោលនយោបាយ និង ច្បាប់ និង គោលការណ៍ លក្ខណៈវិនិច្ឆ័យ និងសន្ទស្សន៍ (PCIs)

និងអត្តុល្យភាពនៃខ្លឹមសារនៃសំណើនេះ (ពោលគឺ ប្រព័ន្ធធានាសុវត្ថិភាពបរិស្ថានបន្ថែមទៀត)

- ក្រសួងពាក់ព័ន្ធនានាគ្មានប្រព័ន្ធព័ត៌មានពេញលេញសម្រាប់រេដបូក
- គ្មានយន្តការដោះស្រាយទំនាស់រេដបូក(GRM) សម្រាប់រេដបូក
- ពុំមានធនធានមនុស្ស និងហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីគ្រប់គ្រងនិងធ្វើបច្ចុប្បន្នភាពប្រព័ន្ធធានាសុវត្ថិភាពជាទៀងទាត់។

**ផែនការអនាគត**

**<u>ជំហានទី ១ (២០១៥-២០១៦)</u>**

- អភិវឌ្ឍន៍វិធីសាស្ត្ររបស់ជាតិបន្ថែមទៀតសម្រាប់ប្រព័ន្ធធានាសុវត្ថិភាព៖ កិច្ចការនេះទាមទារឲ្យមានការ (១) កែសម្រួលគោលការណ៍ និងលក្ខណៈវិនិច្ឆ័យសម្រាប់ប្រព័ន្ធធានាសុវត្ថិភាព (២) ការផ្សារភ្ជាប់គោលការណ៍ និងលក្ខណៈវិនិច្ឆ័យទាំងនេះជាមួយគោលនយោបាយ និងវិធានការជាក់លាក់ និង (៣) ធ្វើការពិនិត្យពីលក្ខណៈច្បាប់នៃគោលការណ៍ និងលក្ខណៈវិនិច្ឆ័យដែលបានកែសម្រួលដើម្បីធានាឲ្យមានសង្គតិភាពជាមួយច្បាប់របស់កម្ពុជា។
- បង្កើតជម្រើសសម្រាប់ក្របខណ្ឌប្រព័ន្ធធានាសុវត្ថិភាព៖ កិច្ចការនេះទាក់ទងនឹង (១) សំណើឲ្យមានសូចនាករមួយឈុតចុងក្រោយ ប្រភពទិន្នន័យ និងវិធីប្រមូលទិន្នន័យ អំពីលទ្ធភាព និងភាពជាក់ស្តែងនៃការអនុវត្ត និង (២) ការកំណត់អត្តសញ្ញាណស្ថាប័ន(ដែលមានស្រាប់ និង/ឬ ថ្មី) និងយន្តការសម្របសម្រួល ដើម្បីប្រមូល វិភាគ តាមដាន រៀបចំទុកដាក់ និងរាយការណ៍/ផ្សព្វផ្សាយព័ត៌មានអំពីប្រព័ន្ធធានាសុវត្ថិភាព ចាប់ពីថ្នាក់មូលដ្ឋាន ជាតិ រហូតថ្នាក់អន្តរជាតិ និងច្រាសមកវិញ។ សំណើទាំងនេះនឹងត្រូវរៀបចំឡើង ក្រោមការសម្របសម្រួលជិតស្និទ្ធជាមួយព័ត៌មានការត្រួតពិនិត្យ រាយការណ៍ និងការបញ្ជាក់ សារពើភ័ណ្ឌព្រៃឈើជាតិ និងប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ ។

**<u>ជំហានទី ២ (ពីឆ្នាំ ២០១៧ ដល់ ២០២០)</u>**

- ការបង្កើតយន្តការដោះស្រាយទំនាស់រេដបូក៖ នៅក្នុងករណីនៃការរំលោភលើប្រព័ន្ធធានាសុវត្ថិភាព រាជរដ្ឋាភិបាលកម្ពុជាត្រូវចាត់វិធានការសមស្រប និងជាបន្ទាន់ ដើម្បីធ្វើឲ្យសកម្មភាពដែលពាក់ព័ន្ធមានអនុលោមភាពឡើងវិញ (ដើម្បីស្របតាមលក្ខខណ្ឌក្នុងការធានាឲ្យមាន"ការគោរព"តាមប្រព័ន្ធសុវត្ថិភាព)។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាគ្រោងកំណត់អត្តសញ្ញាណ និងពឹងផ្អែកលើស្ថាប័ននិងយន្តការនានាដែលមានស្រាប់ ដើម្បីដោះទំនាស់រេដបូកដែលទាក់ទងនឹងរេដ

DRAFT

បូក។

- ការចាត់ចែងវគ្គបណ្តុះបណ្តាលដល់មន្ត្រីនានាដែលទទួលបន្ទុកការងារប្រព័ន្ធធានាសុវត្ថិភាព ។
- សាកល្បងប្រព័ន្ធធានាសុវត្ថិភាព ដំបូង និងប្រមូលយកលទ្ធផលនៃប្រព័ន្ធធានាសុវត្ថិភាពដំបូង។

**<u>ជំហានទី ៣ (ក្រោយឆ្នាំ ២០២០ តទៅ)</u>**

- ប្រមូល និងវិភាគលទ្ធផលនានានៃការអនុវត្តប្រព័ន្ធធានាសុវត្ថិភាព ដែលបានពីក្រសួងពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធសំខាន់ៗ
- ប្រមូលយក និងវិភាគលទ្ធផលនៃការអនុវត្តយន្តការដោះស្រាយទំនាស់រេដបូកសម្រាប់រេដបូក
- ពិនិត្យ និងកែសម្រួលប្រព័ន្ធធានាសុវត្ថិភាព ជាទៀងទាត់ ដែលរួមទាំង ការចាត់ចែងស្ថាប័នផងដែរ
- ស្វែងរកដំណោះស្រាយដែលអាចមាន ដើម្បីកែលម្អប្រព័ន្ធធានាសុវត្ថិភាព លិខិតបទដ្ឋាន គោលនយោបាយ និង ច្បាប់ និង គោលការណ៍ លក្ខណៈវិនិច្ឆ័យ និងសន្ទស្សន៍ (PCIs)
- លើកកសំណើកែសម្រួល លិខិតបទដ្ឋាន គោលនយោបាយ និង ច្បាប់ និងរៀបចំសេចក្តីព្រាង លិខិតបទដ្ឋាន គោលនយោបាយ និង ច្បាប់ថ្មីៗសម្រាប់រេដបូកប្រសិនបើចាំបាច់
- ធានាឲ្យមានធនធានមនុស្សនិងហិរញ្ញវត្ថុសម្រាប់ប្រព័ន្ធធានាសុវត្ថិភាព នៅក្នុងរយៈពេលវែង។

### ៦.២.២ ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ (NFMS)

យោងតាមក្របខ័ណ្ឌក្រុងវ៉ស៍រ សម្រាប់រេដបូក ការបង្កើត ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ ដែលរឹងមាំ ប្រកបដោយតម្លាភាព គឺជាធាតុផ្សំមួយ ក្នុងចំណោមធាតុផ្សំទាំងបួន ដែលចាំបាច់ ដើម្បីភាគីនានាអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីស្នើសុំការទូទាត់ផ្អែកលើលទ្ធផល ។ ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ របស់កម្ពុជា មានមុខងារពីរ - ការត្រួតពិនិត្យ រាយការណ៍ ការវាស់វែង និងការបញ្ជាក់ និងការតាមដាន។

- គោលបំណងនៃមុខងារ ការត្រួតពិនិត្យ រាយការណ៍ ការវាស់វែង និងការបញ្ជាក់គឺប៉ាន់ស្មានការបំភាយ/ការស្រូបយកឧស្ម័នផ្ទះកញ្ចក់ ជាពិសេស ឧស្ម័នកាបូនិក ($CO_2$) ដែលកើតចេញពីសកម្មភាពរបស់មនុស្សនៅក្នុងការប្រើប្រាស់ដី ការប្រែប្រួលការប្រើប្រាស់ដី និងវិស័យព្រៃឈើនៅកម្ពុជា។ ការត្រួតពិនិត្យ រាយការណ៍

ការផ្ទៀងផ្ទាត់ និងការបញ្ជាក់ ផ្សំដោយធាតុសំខាន់ៗចំនួនបី៖ ប្រព័ន្ធតាមដានផ្ទៃដីពីផ្កាយរណប (SLMS), សារពើភ័ណ្ឌព្រៃឈើជាតិ និងសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់។

- ប្រព័ន្ធតាមដានផ្ទៃដីពីផ្កាយរណប (SLMS) គឺជាយន្តការមួយដើម្បីតាមដានការប្រើប្រាស់ដី និងការប្រែប្រួលការប្រើប្រាស់ដី/លក្ខខណ្ឌគម្របដី ដោយប្រើប្រាស់រូបភាពពីផ្កាយរណប។ ប្រព័ន្ធតាមដានផ្ទៃដីពីផ្កាយរណប (SLMS) ប្រមូលយកទិន្នន័យសកម្មភាពសម្រាប់ផ្នែក " វង្វាស់ " នៃ ត្រួតពិនិត្យ រាយការណ៍ ការផ្ទៀងផ្ទាត់។ វាក៏អាចរួមចំណែកក្នុងមុខងារតាមដាននៃប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិផងដែរ។
- សារពើភ័ណ្ឌព្រៃឈើជាតិគឺជាឧបករណ៍ចម្បងមួយរបស់ជាតិ សម្រាប់តាមដានគម្របព្រៃឈើរបស់កម្ពុជា ក៏ដូចជា ផ្តល់ទិន្នន័យអំពីស្តុកកាបូនព្រៃឈើផងដែរ។ សារពើភ័ណ្ឌព្រៃឈើជាតិ គឺជាការវាយតម្លៃនៅលើផ្ទៃដី ដើម្បីប៉ាន់ស្មានការបំភាយ/ការស្រូបយកឧស្ម័នផ្ទះកញ្ចក់នៅក្នុងការប្រើប្រាស់ដី ការប្រែប្រួលការប្រើប្រាស់ដី និងវិស័យព្រៃឈើ។ សារពើភ័ណ្ឌនេះត្រូវបានដាក់ជូនទៅលេខាធិការដ្ឋាននៃអនុសញ្ញា UNFCCC ជាផ្នែកមួយរបាយការណ៍ជាតិ (NC) – ដែលត្រូវដាក់ជូនរៀងរាល់បួនឆ្នាំម្តង និង BUR – ដែលត្រូវដាក់ជូនរៀងរាល់ពីរឆ្នាំម្តង។
- គោលបំណងនៃមុខងារតាមដានគឺ ធ្វើការតាមដាន និងរាយការណ៍អំពីសកម្មភាពរេដបូក ជាពិសេសអំពីឥទ្ធិពល និងប្រសិទ្ធភាពនៃគោលនយោបាយ និងវិធានការរេដបូក។
- កម្ពុជាមានឧបសគ្គខាងបច្ចេកទេស និងហិរញ្ញវត្ថុ ដែលទាក់ទងនឹងធនធានមនុស្ស។ ដូច្នេះ ការរៀបចំ ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ នឹងត្រូវធ្វើឡើងជាជំហានៗ។

## ស្ថានភាពនៃសកម្មភាព

### ១. ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ

- ប្រព័ន្ធ**តាមដានត្រួតពិនិត្យព្រៃឈើជាតិ** របស់កម្ពុជា ត្រូវបានបង្កើតឡើង ដោយផ្តោតលើការប្រើប្រាស់ដី/ការប្រែប្រួលគម្របដី រវាងការប្រើប្រាស់ដី/ចំណាត់ថ្នាក់គម្របដីប្រាំមួយបែប ពោលគឺ ដីព្រៃឈើ ដីដាំដំណាំ ដីវាលស្មៅ ដីតាំងទីលំនៅ ដីផ្សេងទៀត និងតំបន់ដីសើម ជាពិសេស ការប្រែប្រួលរវាងព្រៃឈើ និងដីមិនមែនព្រៃឈើ និងតាមដានផងដែរអំពីប្រសិទ្ធភាព និងលទ្ធផលនៃគោលនយោបាយ និងវិធានការរេដបូក។
- ការរៀបចំប្រព័ន្ធ**តាមដានត្រួតពិនិត្យព្រៃឈើជាតិ** ជាដំបូង ត្រូវបានរំពឹងថានឹងធ្វើឡើងរួចរាល់នៅចុងខែតុលា ឆ្នាំ ២០១៥។

- វិធីសាស្រ្តសម្រាប់ការតាមដានគោលនយោបាយ និងវិធានការនានា នឹងត្រូវកំណត់ ស្របតាមប្រភេទនៃគោលនយោបាយ និងវិធានការទាំងនោះ។
- ប្រព័ន្ធគ្រប់គ្រងកម្រងទិន្នន័យមួយត្រូវបានបង្កើតឡើង ដើម្បីរក្សាទុក និងគ្រប់គ្រងទិន្នន័យ និងព័ត៌មានដែលចាំបាច់សម្រាប់ប្រព័ន្ធ**តាមដានត្រួតពិនិត្យព្រៃឈើជាតិ** និងដើម្បីធានាថា អ្នកពាក់ព័ន្ធទាំងអស់អាចប្រើប្រាស់ទិន្នន័យ និងព័ត៌មានអំពីដំណើរការរេដបូក។
- WEB វេបសាយមួយ កំពុងស្ថិតក្នុងការរៀបចំ ហើយម៉ាស៊ីនសឺវើរ ក៏កំពុងរៀបចំឡើងផងដែរ ដើម្បីអាចឲ្យមានការចែករំលែកដោយតម្លាភាពនូវទិន្នន័យដែលទាក់ទងនឹងប្រព័ន្ធ**តាមដានត្រួតពិនិត្យព្រៃឈើជាតិ**។

## ២. ប្រព័ន្ធតាមដានស្ថានភាពគម្របដីពីផ្កាយរណប

- រដ្ឋបាលព្រៃឈើបាន និងកំពុងផលិតផែនទីគម្របព្រៃឈើជាតិ ដោយប្រើប្រាស់រូបភាពពីផ្កាយរណប (Landsat) ក្នុងចន្លោះពេលបួនឆ្នាំ គិតចាប់ពីឆ្នាំ ២០០២មក និងបានប្រើប្រាស់ផែនទីនានាសម្រាប់ការអភិវឌ្ឍ ការគ្រប់គ្រង និងការអភិរក្សព្រៃឈើ។ ថ្មីៗនេះ ផែនទីគម្របព្រៃឈើជាតិ ឆ្នាំ ២០០៦ និង ២០១០ ត្រូវបានកែលម្អដោយកែប្រែការប្រើប្រាស់ដី/ចំណាត់ថ្នាក់គម្របព្រៃឈើ ដើម្បីធ្វើសុខដុមនីយកម្មជាមួយចំណាត់ថ្នាក់ប្រើប្រាស់ដីទាំងប្រាំមួយ ដែលកំណត់ដោយIPCC។ លើសពីនេះ ផែនទីថ្មីឆ្នាំ ២០១៤ ត្រូវបានផលិត ដោយប្រើប្រាស់ជំពូកនៃការប្រើប្រាស់ដី/ចំណាត់ថ្នាក់គម្របព្រៃឈើ ដូចគ្នា នឹងចំណាត់ថ្នាក់សម្រាប់ឆ្នាំ ២០០៦ និង២០១០ ផងដែរ។
- រូបថតពីផ្កាយរណប (Landsat) នឹងត្រូវបន្តប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការបង្កើតផែនទីប្រើប្រាស់ដី/គម្របព្រៃឈើ ដោយសារតែប្រសិទ្ធភាពខាងថ្លៃចំណាយ និងភាពងាយស្រួលក្នុងការកំណត់ពីការប្រែប្រួលការប្រើប្រាស់ដី។
- វិធីបំបែកព័ត៌មានដែលទទួលបានពីចម្ងាយ ត្រូវបានយកមកប្រើប្រាស់នៅឆ្នាំ ២០១៣ និងត្រូវបានប្រើប្រាស់សម្រាប់ផលិតផែនទីប្រើប្រាស់ដី/គម្របព្រៃឈើថ្នាក់ជាតិនៅឆ្នាំ២០១៤ និងដើម្បីបង្កើនគុណភាព[xii] ផែនទីគម្របព្រៃឈើជាតិឆ្នាំ ២០០៦ និង២០១០។
- នៅក្នុងកំណែផែនទីឆ្នាំ ២០០៦ និង ២០១០ និងក្នុងការបង្កើតផែនទីឆ្នាំ ២០១៤ ការប្រើប្រាស់ដី/ចំណាត់ថ្នាក់ព្រៃឈើប្រាំមួយបែប ដែលបានកំណត់នៅក្នុងឯកសារណែនាំរបស់ IPCC ពោលគឺ ដីព្រៃ ដីដាំដំណាំ វាលស្មៅ កន្លែងតាំងទីលំនៅ ដីផ្សេងទៀត និងតំបន់ដីសើម ត្រូវបានបំបែកជា ២២ថ្នាក់។
- ចំពោះការតាមដានសកម្មភាពរេដបូក ព័ត៌មានផ្សេងទៀតពីផ្កាយរណប ដូចជា

ព័ត៌មានដែលមាន
ផ្តល់តាមប្រព័ន្ធ Google Earth ក៏ត្រូវបានយកមកប្រើប្រាស់ផងដែរ។

## ៣. សារពើភ័ណ្ឌព្រៃឈើជាតិ (NFI)

- កម្ពុជានៅពុំទាន់មានការធ្វើសារពើភ័ណ្ឌព្រៃឈើជាលក្ខណៈប្រព័ន្ធ គ្របដណ្តប់លើព្រៃឈើទាំងមូលនៅឡើយទេ។ ការធ្វើអង្កេតនៅក្នុងសារពើភ័ណ្ឌព្រៃឈើ បាននឹងកំពុងបង្កើតឡើងសម្រាប់ ការប៉ាន់ប្រមាណបរិមាណឈើដោយរដ្ឋបាលព្រៃឈើ ឬសម្រាប់ការស្រាវជ្រាវដោយអ្នកស្រាវជ្រាវក្នុងស្រុក និងអន្តរជាតិ។
- ការរៀបចំសារពើភ័ណ្ឌព្រៃឈើជាតិ (NFI) និងឯកសារណែនាំសម្រាប់ការអង្កេតសារពើភ័ណ្ឌព្រៃឈើជាតិ នៅតាម ចំណុចទីតាំងភូមិសាស្ត្រ កំពុងត្រូវបានធ្វើការចងក្រង ហើយដែលនឹងត្រូវបញ្ចប់ និងបោះពុម្ពផ្សាយ នៅក្នុងឆ្នាំ ២០១៥។
- ចំពោះការរៀបចំស្ថាប័ន រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល និងក្រសួងបរិស្ថាន មានភារៈទទួលខុសត្រូវលើសារពើភ័ណ្ឌព្រៃឈើជាតិ តាមទីកន្លែងផ្សេងៗ នៅក្នុងដែនសមត្ថកិច្ចរៀងៗខ្លួន ដែលក្នុងនោះរួមមានទាំងការវិភាគនៅក្នុងមន្ទីរពិសោធន៍ផងដែរ ក្នុងពេលចាំបាច់។ លទ្ធផលបានមកពីសារពើភ័ណ្ឌព្រៃឈើជាតិ នឹងត្រូវរក្សាទុកដោយសមាជិកក្រុមបច្ចេកទេស ត្រួតពិនិត្យ រាយការណ៍ ការវាស់វែង និងការបញ្ជាក់ ។
- ទិន្នន័យអំពីជីវម៉ាស់ដើមឈើ ត្រូវបានវិភាគ ហើយមេគុណបំភាយត្រូវបានកំណត់សម្រាប់ព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះ ព្រៃដុះឡើងវិញ ព្រៃលិចទឹក ចម្ការឈើ ព្រៃកោងកាង និងឫស្សី ដែលត្រូវបានប្រើប្រាស់សម្រាប់ការគណនាកម្រិតបំភាយយោងព្រៃឈើ /កម្រិតយោងព្រៃឈើ ដំបូង។

## ៤. សារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់

- ដំណើរការនេះ ត្រូវបានប្រើប្រាស់សម្រាប់ការប្រមូលផ្តុំសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់របស់កម្ពុជា សម្រាប់ការប្រើប្រាស់ដី ការប្រែប្រួលការប្រើប្រាស់ដី និងវិស័យព្រៃឈើ ត្រូវបានពិនិត្យ និងសិក្សា។ លើសពីនេះ ការបណ្តុះបណ្តាលអំពីការប្រើប្រាស់ឧបករណ៍ផ្នែកទន់(ឧបករណ៍អេឡិចត្រូនិច) សម្រាប់សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់សម្រាប់ការគណនាការបំភាយ ក៏បានធ្វើឡើងផងដែរ។
- វិធីនេះនឹងត្រូវប្រើប្រាស់នៅក្នុង BUR នៅពេលខាងមុខ ហើយ របាយការណ៍ជាតិ (NC) នៅពុំទាន់បានកំណត់នៅឡើយទេ។

DRAFT

## ផែនការរយៈពេលមធ្យម (២០១៦-២០២០)

### ១. ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ (NFMS)

- **ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ** នឹងត្រូវបង្កើតឡើង ដោយអនុវត្តតាមអភិក្រមជាជំហានៗ ស្របជាមួយការអភិវឌ្ឍបច្ចេកវិទ្យានៅពេលអនាគត និងការអភិវឌ្ឍសមត្ថភាពរបស់អ្នកពាក់ព័ន្ធនានា ដែលប្រើប្រាស់ប្រព័ន្ធនេះ
- យន្តការមួយសម្រាប់ការតាមដានគោលនយោបាយ និងវិធានការនានា នឹងត្រូវរៀបចំឡើង (បន្ថែមពីលើអ្វី ដែលបានប្រមូលយកនៅក្នុង ប្រព័ន្ធតាមដានស្ថានភាពគម្របដីពីផ្កាយរណប សារពើភ័ណ្ឌព្រៃឈើជាតិ និងយន្តការប្រមូលព័ត៌មានដែលមានស្រាប់របស់រាជរដ្ឋាភិបាលកម្ពុជា)។

### ២. ប្រព័ន្ធតាមដានរូបភាពផែនទីពីផ្កាយរណប

- ការប្រើប្រាស់ដី/ ផែនទីគម្របព្រៃឈើ សម្រាប់ឆ្នាំ ២០១៦ ឬ ២០១៨ នឹងត្រូវផលិត។ ចន្លោះរយៈពេលនៃការផលិតផែនទីគឺ ២ ឬ ៤ ឆ្នាំ។
- ការកែសម្រួលបន្ថែមទៀតលើផែនទីឆ្នាំ ២០០៦ និង ២០១០ ដោយផ្អែកលើផែនទីឆ្នាំ ២០១៤ នឹងត្រូវធ្វើឡើង ដើម្បីធានាឲ្យមានសង្គតិភាពពេញលេញក្នុងចំណោមផែនទីទាំងនេះ។
- បង្កើតវិធីសាស្ត្រដើម្បីកំណត់រកកន្លែងរេចរឹលព្រៃឈើនៅកម្ពុជា ដោយពុំចាំបាច់ធ្វើសារពើភ័ណ្ឌព្រៃឈើជាតិ ឡើងវិញ។
- ការកសាងសមត្ថភាពមន្ត្រីជំនាន់ថ្មីអំពីការបកស្រាយរូបភាពពីផ្កាយរណប។

### ៣. សារពើភ័ណ្ឌព្រៃឈើជាតិ (NFI)

- ការអនុវត្តសារពើភ័ណ្ឌព្រៃឈើជាតិ ជាលើកដំបូងនៅក្នុង PSPs។
- ពិនិត្យលទ្ធផលដំបូងនៃការអនុវត្ត សារពើភ័ណ្ឌព្រៃឈើជាតិ និងធ្វើការកែប្រែក្នុងករណីចាំបាច់។
- ការអនុវត្តសារពើភ័ណ្ឌព្រៃឈើជាតិ ក្នុងកម្រិតពេញលេញ។
- ពិនិត្យមើលគ្រោងការណ៍នៃការរៀបចំសារពើភ័ណ្ឌព្រៃឈើជាតិ និងធ្វើការកែសម្រួលសំណៅសម្រាប់ការអនុវត្តនៅជុំទីពីរ។

### ៤. សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់

- ការរៀបចំសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ សម្រាប់របាយការណ៍ជាតិលើកទីបី និងរបាយការណ៍BUR លើកដំបូងសម្រាប់កម្ពុជា។
- មានការរំពឹងថា របាយការណ៍ជាតិលើកទីបី នឹងត្រូវដាក់ជូននៅឆ្នាំ ២០??? និងរបាយការណ៍ BUR ដំបូង នឹងត្រូវដាក់ជូននៅឆ្នាំ ២០???។
- ការជ្រើសរើសវិធីមួយ - វិធីកើន-ថយ ឬវិធីភាពខុសគ្នានៃស្តុក (Gain Loss Method or

Stock Difference Method)។

- ការជ្រើសយកគោលការណ៍ណែនាំរបស់ IPCC សម្រាប់ប្រើប្រាស់។

### ៦.២.៣ កម្រិតបំភាយយោងព្រៃឈើ (FREL/ FRL)

កម្រិត (បំភាយ) យោងពីព្រៃឈើគឺជាលក្ខខណ្ឌគោលសម្រាប់វាយតម្លៃស្ថានភាពរបស់ប្រទេសនៅក្នុងការអនុវត្តសកម្មភាពរេដបូក និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ តាមរយៈសកម្មភាពនានាដែលទាក់ទងនឹងព្រៃឈើ។ FREL/ FRL គឺជាផ្នែកមួយក្នុងចំណោមធាតុផ្សំទាំងបួន ដែលប្រទេសនានាត្រូវបង្កើតឡើង នៅពេលអនុវត្តសកម្មភាពរេដបូក និងដើម្បីទទួលបានការទូទាត់ផ្អែកលើលទ្ធផល RBP សម្រាប់រេដបូក ក្រោមអនុសញ្ញា UNFCCC។ ប្រទេសកំពុងអភិវឌ្ឍ ដែលចង់ទទួលបានការទូទាត់ផ្អែកលើលទ្ធផលសម្រាប់សកម្មភាពរេដបូក ត្រូវដាក់ជូនសំណើកម្រិតបំភាយយោងព្រៃឈើ របស់ខ្លួនទៅអនុសញ្ញា UNFCCC សម្រាប់ការវាយតម្លៃបច្ចេកទេស។ គោលបំណងនៃការវាយតម្លៃបច្ចេកទេស គឺធ្វើការប៉ាន់ប្រមាណអំពីកម្រិតដែលព័ត៌មានផ្តល់ឲ្យ ឆ្លើយតបនឹងគោលការណ៍ណែនាំនៅក្រោមអនុសញ្ញា UNFCCC និងដើម្បីអាចឲ្យមានការផ្លោះប្តូរព័ត៌មានបច្ចេកទេសអំពីការបង្កើតកម្រិតបំភាយយោងព្រៃឈើ /កម្រិតយោងព្រៃឈើ ។

អនុសញ្ញាUNFCCC អនុញ្ញាតឲ្យប្រើប្រាស់វិធីជាជំហានៗ ដើម្បីកែលម្អ FREL/FRL ជាបណ្តើរៗ។ គេអាចធ្វើបច្ចុប្បន្នភាព FREL/FRLs ក្នុងរយៈពេលមួយកំណត់ ដើម្បីឆ្លុះបញ្ចាំងអំពីការកែលម្អទិន្នន័យ សមត្ថភាព និង/ឬ ការប្រែប្រួលនៃកាលៈទេសៈរបស់ជាតិទំហំ ឬវិធីសាស្ត្រ។ ដោយសារតែដំណើរការវាយតម្លៃបច្ចេកទេស អនុញ្ញាតឲ្យមានការផ្លោះប្តូរព័ត៌មានបច្ចេកទេស ដំណើរការនេះត្រូវបានគេចាត់ទុកថានឹងអាចផ្តល់ការណែនាំពីការកែលម្អបច្ចេកទេសអំពី FREL/ FRLs នៅពេលអនាគត។ នៅពេលដែល FREL/ FRL បានឆ្លងកាត់ការវាយតម្លៃបច្ចេកទេសរួចហើយ ប្រទេសកំពុងអភិវឌ្ឍណាមួយ ដែលចង់ទទួលបានការទូទាត់ផ្អែកលើលទ្ធផលពីសកម្មភាពរេដបូក ត្រូវដាក់ជូនឧបសម្ព័ន្ធបច្ចេកទេសភ្ជាប់នឹងBURរបស់ខ្លួន។ របាយការណ៍ BUR នឹងរួមបញ្ចូលសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់នៅថ្នាក់ជាតិ និងក្លាយជាកម្មវត្ថុនៃការពិគ្រោះយោបល់ និងការវិភាគជាអន្តរជាតិ ដែលរួមទាំងការវិភាគអំពីសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ ក៏ដូចជា ឥទ្ធិពលនៃសកម្មភាពកាត់បន្ថយផងដែរ។

### ស្ថានភាពបច្ចុប្បន្ន ការប្រឈម និងឧបសគ្គ

កម្រិតបំភាយយោងព្រៃឈើ /កម្រិតយោងព្រៃឈើ(FREL/FRL)សម្រាប់កម្ពុជា កំពុងស្ថិតក្នុងការរៀបចំដោយអនុវត្តតាមអភិក្រមជាជំហានៗ។ ដំណាក់កាលដំបូងនៃ FREL/FRL សម្រាប់កម្ពុជា កំពុងចាប់ផ្តើមជាមួយទំហំនៃសកម្មភាពក្នុងកម្រិតកំណត់។ ការ

DRAFT

ប៉ាន់ស្មានប្រសើរជាងមុន ត្រូវបានគ្រោងដាក់បញ្ចូលទៅក្នុង FRLs/ FRELs ថ្មី ជាបន្តបន្ទាប់ នៅពេលមានទិន្នន័យថ្មីៗ និងមានវិធីសម្រាប់ការគណនា។

ស្ថានភាពបច្ចុប្បន្ននៃការរៀបចំ FREL/FRL ដំបូង៖

- អាងស្តុកកាបូន និងឧស្ម័នផ្ទះកញ្ចក់៖ កម្ពុជានឹងវាយតម្លៃការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលទាក់ទងនឹងឧស្ម័នកាបូនិក($CO_2$) និងជីវម៉ាស់នៅក្នុងអាងស្តុកជីវម៉ាស់ខ្ពស់ផុតពីផ្ទៃដី និងអាងស្តុកជីវម៉ាស់ក្នុងដី។
- មាត្រដ្ឋាន៖ FREL/ FRL កម្រិតជាតិ
- វិសាលភាព៖ ការបាត់បង់ព្រៃឈើ និងការដាំដើមឈើ
- អំឡុងពេលយោង៖ ឆ្នាំ២០០៦-២០១៤
- ទិន្នន័យសកម្មភាព៖ ការសង្កេតជំពូកនៃការប្រើប្រាស់ដីតាមរូបភាព និងការបម្លែងចន្លោះឆ្នាំ ២០០៦, ២០១០ និង ២០១៤។ ព្រៃឈើ និងជំពូកផ្សេងទៀតនៃការប្រើប្រាស់ដី ត្រូវបានញែកចេញពីគ្នា អាស្រ័យតាមជំពូកនៃការប្រើប្រាស់ដី។
- មេគុណបំភាយ៖ ការបំភាយជាក់លាក់នៃប្រទេសណាមួយសម្រាប់ជំពូកសំខាន់ៗ (លំដាប់ទី ២) ដោយផ្អែកលើទិន្នន័យសារពើភណ្ឌព្រៃឈើដែលមានស្រាប់ ដោយមានជំនួយពីមេគុណបំភាយជំនួស សម្រាប់ជំពូកដទៃទៀត
- វិធីបង្កើតកម្រិតបំភាយយោងព្រៃឈើ /កម្រិតយោងព្រៃឈើ៖ តួលេខមធ្យមភាគជាប្រវត្តិសាស្រ្ត រួមជាមួយការពិនិត្យមើលកាលៈទេសៈរបស់ជាតិ (អាចកែសម្រួលអនុលោមតាមកាលៈទេសៈរបស់ជាតិ ដែលនៅត្រូវធ្វើការសម្រេច)។

**ស្ថានភាពនៃសកម្មភាព៖** កម្ពុជាកំពុងគ្រោងដាក់ជូនកម្រិតបំភាយយោងព្រៃឈើ (FREL) ដំបូងរបស់ខ្លួនទៅអនុសញ្ញា NFCCC នៅចុងឆ្នាំ ២០១៥ សម្រាប់ការវាយតម្លៃបច្ចេកទេសនៅឆ្នាំ ២០១៦។

## ផែនការអនាគត

ផែនការដើម្បីដោះស្រាយការប្រឈម/ ឧបសគ្គនានាដែលកត់សំគាល់ពីខាងដើម៖ គួរផ្តោតលើលទ្ធផលរំពឹងទុក និងសកម្មភាពនានា ដើម្បីសម្រេចបានលទ្ធផល។ FREL/ FRL របស់កម្ពុជា កំពុងស្ថិតក្នុងការរៀបចំ ទៅតាមគោលការណ៍ជាជំហានៗ។ FREL/ FRL របស់កម្ពុជា នឹងត្រូវពិនិត្យកែសម្រួលជាទៀងទាត់ ដើម្បីរួមបញ្ចូលទិន្នន័យថ្មីៗ និន្នាការ និងវិធីនានា។ ផ្នែកនានាដែលត្រូវពិនិត្យឡើងវិញនៅក្នុងរយៈពេលមធ្យម រួមមាន៖

- **អាងស្តុកកាបូន និងឧស្ម័ន៖** ការរួមបញ្ចូលឈើងាប់ កម្ទេចកំទី និងសារធាតុសរីរាង្គដី ក្នុងករណីសមស្រប។
- **មេគុណបំភាយ៖** ការរួមបញ្ចូល ឬ ការកែលម្អមេគុណបំភាយដែលមានស្រាប់ ទៅ

តាមករណីសមស្រប។

- **វិសាលភាព៖** ការកែសម្រួលវិសាលភាព ទៅតាមករណីសមស្រប។
- **វិធីសាស្ត្របង្កើត**កម្រិតបំភាយយោងព្រៃឈើ ៖ ប្រសិនបើប្រមូលបានទិន្នន័យសកម្មភាពគ្រប់គ្រាន់ និន្នាការជាប្រវត្តិសាស្ត្រកន្លងមកនឹងត្រូវយកមកវិភាគ ទៅតាមករណីសមស្រប។
- **អំឡុងពេលយោង៖** ប្រសិនបើបានប្រមូលទិន្នន័យសកម្មភាពគ្រប់គ្រាន់ ហើយកាលៈទេសៈរបស់ជាតិតម្រូវឲ្យមានការពិនិត្យឡើងវិញ អំឡុងពេលយោងនឹងត្រូវកែសម្រួល តាមករណីសមស្រប។
- **វដ្តនៃការធ្វើបច្ចុប្បន្នភាព៖** ចិរវេលានៃការធ្វើបច្ចុប្បន្នភាព FREL/ FRL ជាលើកដំបូង គឺអាស្រ័យលើលទ្ធផលនៃការវាយតម្លៃបច្ចេកទេសនៃការអនុវត្ត FREL/ FRL ដំបូង និងវត្តមានទិន្នន័យថ្មីៗ។ ការរួមបញ្ចូលទិន្នន័យសកម្មភាពថ្មីៗ (២០១៦, ២០១៨ និង ២០២០) ការចងក្រងសារពើភ័ណ្ឌព្រៃឈើជាតិ លើកដំបូងរបស់កម្ពុជា (ឆ្នាំ ២០១៦-២០២០) គឺជាចំណុចគោលចម្បង។

## ៦.៣ ការរៀបចំស្ថាប័ន និងការសម្របសម្រួល

ការរៀបចំស្ថាប័នសម្រាប់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ត្រូវទទួលស្គាល់ពីភាពខុសគ្នានៃតួនាទី និងការទទួលខុសត្រូវ របស់អាជ្ញាធរជាតិខុសៗគ្នា ដែលមានសមត្ថកិច្ចលើធនធានព្រៃឈើ។ ដូច្នេះ ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ត្រូវបានរំពឹងថាធ្វើទៅតាមដែនសមត្ថកិច្ចរបស់ស្ថាប័នរដ្ឋាភិបាល ដោយស្ថាប័នខុសៗគ្នានឹងរួមចំណែកទៅក្នុងការរៀបចំផែនការសកម្មភាពរេដបូកសម្រាប់តំបន់ព្រៃឈើខុសគ្នា ដោយផ្អែកតាមច្បាប់ និងគោលនយោបាយដែលមានស្រាប់។ ការអនុវត្តនឹងត្រូវផ្អែកលើក្របខណ្ឌជាតិ ដោយសាររេដបូក ទាមទារឲ្យមានការអនុវត្តនៅកម្រិតជាតិ ដោយត្រូវធ្វើរបាយការណ៍នៅថ្នាក់ជាតិសម្រាប់ដាក់ជូនទៅUNFCCC។

### ៦.៣.១ ការរៀបចំស្ថាប័នដែលមានស្រាប់ សម្រាប់ពិនិត្យមើលការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ

សមាជិកនៃក្រុមការងាររេដបូកកម្ពុជា មានតំណាងចំនួន១០រូបមកពីក្រសួងចំនួនប្រាំពីរ ដែលមានអាណត្តិគ្រប់គ្រងការរៀបចំដំណាក់កាលត្រៀមលក្ខណៈសម្រាប់រេដបូក។ ក្រសួងទាំងប្រាំពីរដែលមានតំណាងនៅក្នុងក្រុមការងាររេដបូកគឺ៖ (១) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) (២) ក្រសួងបរិស្ថាន - (MoE) (៣) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF), (៤) ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (៥) ក្រសួងមហាផ្ទៃ (៦) ក្រសួងអភិវឌ្ឍន៍ជនបទ និង (៧) ក្រសួងរ៉ែ និងថាមពល។ ការទទួលខុស

ត្រូវជារួមរបស់ក្រុមការងារនេះគឺ គ្រប់គ្រងកម្មវិធីជាតិរេដបូក សម្របសម្រួលសកម្មភាពរេដបូកនៅថ្នាក់ជាតិ ធានាថាការឆ្លើយតបរបស់រដ្ឋាភិបាលមានការសម្របសម្រួលបានល្អ និង រួមបញ្ចូលរេដបូកទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ជាតិ។

**ក្រុមបច្ចេកទេសរេដបូក** ដែលបានបង្កើតឡើងដោយក្រុមការងាររេដបូក មានភារៈកិច្ចទទួលខុសត្រូវលើកអនុសាសន៍បច្ចេកទេសអំពីបញ្ហាសំខាន់ៗ។ ក្រុមបច្ចេកទេសទាំងបួននោះគឺ៖ (១) ក្រុមបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាព (២) ក្រុមបច្ចេកទេសបែងចែកផលប្រយោជន៍ (៣) ក្រុមបច្ចេកទេសអនុវត្តគម្រោងគំរូ (៤) ក្រុមបច្ចេកទេសត្រួតពិនិត្យ រាយការណ៍ ការវាស់វែង និងការបញ្ជាក់។ សមាជិកក្រុមទាំងនេះ រួមមានមន្ត្រីបច្ចេកទេសមកពីស្ថាប័នពាក់ព័ន្ធផ្សេងៗ ដែលទទួលខុសត្រូវលើការពិភាក្សាអំពីបញ្ហានានាជាអ្នកពាក់ព័ន្ធដទៃទៀតផងដែរ ដែលត្រូវបានកំណត់ មានដូចជា សង្គមស៊ីវិល និងតំណាងពីក្រុមជនជាតិដើមភាគតិច។ សមាជិកអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ដែលជ្រើសរើសចេញពីតំណាងអង្គការនានា ក្នុងក្រុមពិគ្រោះយោបល់។

**ក្រុមពិគ្រោះយោបល់** ដែលបានបង្កើតឡើងនៅឆ្នាំ ២០១៣ មានតំណាងដែលបានពីការបោះឆ្នោតចំនួនពីររូប មកពីស្ថាប័នចំនួនប្រាំបួននៅកម្ពុជា។ ស្ថាប័នទាំងប្រាំបួននោះ រួមមាន៖ អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលជាតិ អង្គការក្រៅរដ្ឋាភិបាលមូលដ្ឋាន ក្រុមជនជាតិដើមភាគតិច វិស័យឯកជន គ្រឹះស្ថានសិក្សាស្រាវជ្រាវ សហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍នេសាទ។ ក្រុមការងាររេដបូក បញ្ជូនរបាយការណ៍ និងការសម្រេចនានាទៅក្រុមពិគ្រោះយោបល់ដើម្បីស្នើសុំយោបល់ និងការឆ្លើយតបចំពោះយោបល់ដែលបានលើកឡើង។ សមាជិកក្រុមពិគ្រោះយោបល់ក៏អាចត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកិច្ចប្រជុំក្រុមការងាររេដបូកផងដែរ នៅក្នុងករណីសមស្រប។

**ក្រុមការងារយេនឌ័ររេដបូក** ត្រូវបានបង្កើតឡើងនៅខែសីហា ឆ្នាំ ២០១៤ ដោយក្រុមការងាររេដបូក ដើម្បី៖ ១) បង្កើតការយល់ដឹងអំពីយេនឌ័រ និងសញ្ញាណនៃការពង្រឹងភាពអង់អាចរបស់ស្ត្រី និងបញ្ហានានា ក្នុងចំណោមសមាជិកក្រុមការងារ ក្រុមពិគ្រោះយោបល់ និងក្រុមបច្ចេកទេស និង ២) ផ្តល់យោបល់អំពីយេនឌ័រទៅក្នុងសមាសភាគនៃយុទ្ធសាស្ត្ររេដបូកជាតិ និងគោលការណ៍ណែនាំសម្រាប់ការអនុវត្តជាបន្តបន្ទាប់ នៅពេលមានការរៀបចំឡើង។ ជាសរុប មានសមាជិកចំនួនបួនរូប នៅក្នុងក្រុមការងារយេនឌ័ររេដបូកកម្ពុជា ដែលមកពីស្ថាប័នពាក់ព័ន្ធចំនួនបួន៖ រដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងក្រសួងកិច្ចការនារី។

### ៦.៣.២ ការចាត់ចែងស្ថាប័នសម្រាប់ត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ

ការចាត់ចែងស្ថាប័នសម្រាប់ពិនិត្យដំណើរការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ត្រូវ

មានគោលការណ៍ដូច តទៅ៖ អភិបាលកិច្ចល្អ សុចរិតភាព ដោយធានាការចូលរួមពេញលេញ និងប្រកបដោយប្រសិទ្ធភាពនៃអ្នកពាក់ព័ន្ធទាំងអស់ ប្រសិទ្ធភាពនៃថ្លៃចំណាយ នៅក្នុងការសម្រេចគោលបំណងនានា និងគណនេយ្យភាពនៅក្នុងការអនុវត្តសកម្មភាពរេដបូក។ គណៈកម្មាធិការរេដបូកជាតិ (NRC) ដែលគាំទ្រដោយលេខាធិការដ្ឋាន នឹងត្រូវរៀបចំឡើង ដើម្បីត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ នៅកម្ពុជា។

## គណៈកម្មាធិការរេដបូកជាតិ (NRC)

គណៈកម្មាធិការរេដបូកជាតិ និងលេខាធិការដ្ឋានរបស់ខ្លួន នឹងត្រូវបង្កើតឡើងដោយច្បាប់ និងត្រូវរាយការណ៍ និងស្ថិតក្រោមការដឹកនាំដោយផ្ទាល់របស់នាយករដ្ឋមន្ត្រីតាមរយៈក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍដោយចីរភាព (NCSD)។ គណៈកម្មាធិការរេដបូកជាតិ ត្រូវមានប្រធាន ដែលមានឋានៈស្មើនឹងរដ្ឋ
មន្ត្រី។ គណៈកម្មាធិការរេដបូកជាតិ នឹងត្រូវបង្កើតឡើង ក្នុងបំណងដូចតទៅ៖

១. ទទួលបន្ទុកអភិបាលកិច្ចនៅថ្នាក់ជាតិ និងសម្របសម្រួលសកម្មភាពរេដបូកទាំងអស់នៅកម្ពុជា

២. ត្រួតពិនិត្យ និងបង្កើនការកែលម្អអភិបាលកិច្ចធនធានព្រៃឈើ ដើម្បីកាត់បន្ថយអត្រានៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ

៣. ធានាឲ្យមានប្រសិទ្ធភាពនៃសេវាកម្មមូលនិធិ និងការបែងចែកឲ្យបានត្រឹមត្រូវនូវការលើកទឹកចិត្តសម្រាប់ស្ថាប័ននានាដែលអនុវត្តសកម្មភាពរេដបូក។

## មុខងាររបស់គណៈកម្មាធិការរេដបូកជាតិ

គណៈកម្មាធិការរេដបូកជាតិ ត្រូវមានអាណត្តិដើម្បីអនុវត្តន៍មុខងារជាយុទ្ធសាស្ត្រនៅក្នុងក្របខណ្ឌនៃការសម្របសម្រួលតាមជំនាញ ដោយផ្តោតលើឥទ្ធិពលមកលើដំណើរការអនុវត្ត និងការសម្របសម្រួលក្នុងចំណោមក្រសួងខុសៗគ្នា និងស្ថាប័នដែលពាក់ព័ន្ធនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន។ គណៈកម្មាធិការរេដបូកជាតិ នឹងធ្វើការសម្រេចផងដែរអំពីមុខងារនៃការចាត់ចែងស្ថាប័នដែលមានស្រាប់ (ក្រុមការងារ ក្រុមបច្ចេកទេស ក្រុមពិគ្រោះយោបល់ និងក្រុមយេនឌ័រ) ដូចមានកត់សំគាល់ក្នុងជំពូកខាងលើ។

លើសពីនេះ ដោយមានការគាំទ្រពីលេខាធិការដ្ឋានរបស់ខ្លួន គណៈកម្មាធិការរេដបូកជាតិ ត្រូវបានតែងតាំងជាស្ថាប័នជាតិសម្រាប់៖

- ការរៀបចំក្របខណ្ឌច្បាប់សម្រាប់ការអនុវត្តផែនការសកម្មភាពរេដបូក
- បង្កើនការកែលម្អអភិបាលកិច្ចដីព្រៃឈើ
- សម្រួលដល់ការកសាងសមត្ថភាព ដើម្បីធានាឲ្យមានការបែងចែកការលើកទឹកចិត្តបានត្រឹមត្រូវ និងសមធម៌ ដល់អ្នកពាក់ព័ន្ធនានា

- សម្របសម្រួលការបង្កើតទីភ្នាក់ងារជាតិផ្តល់មូលនិធិសម្រាប់រេដបូក និងអនុម័តវិធានការនិយ័តកម្មនានា ដែលទាក់ទងនឹងលក្ខណៈវិនិច្ឆ័យសម្រាប់ការទូទាត់ ដោយផ្អែកលើលទ្ធផល ការគ្រប់គ្រង និងការផ្ទេរហិរញ្ញវត្ថុរេដបូក ក៏ដូចជា ការបែងចែកការលើកទឹកចិត្តនៅលំដាប់ថ្នាក់រដ្ឋបាលខុសៗគ្នាផងដែរ
- សម្របសម្រួលការបង្កើតទីភ្នាក់ងារជាតិត្រួតពិនិត្យ រាយការណ៍ ការវាស់វែង និងផ្ទៀងផ្ទាត់ សម្រាប់រេដបូក អនុម័តវិធានការនិយ័តកម្ម ដែលទាក់ទងនឹងការតាមដាន ការធ្វើការត្រួតពិនិត្យ រាយការណ៍ ការវាស់វែង និងការបញ្ជាក់ និងការចេញវិញ្ញាបនបត្របញ្ជាក់ការកាត់បន្ថយការបំភាយ និងកំណើនស្តុកកាបូន ក៏ដូចជា ត្រួតពិនិត្យការអនុវត្តផងដែរ
- សម្របសម្រួលការរៀបចំក្របខណ្ឌ និងប្រព័ន្ធព័ត៌មានសម្រាប់ការអនុវត្តប្រព័ន្ធធានាសុវត្ថិភាពនៅក្រោមរេដបូក ការបង្កើតគណៈកម្មការប្រព័ន្ធធានាសុវត្ថិភាពរេដបូក ក៏ដូចជា អនុម័ត និងសម្របសម្រួលការអនុវត្តប្រព័ន្ធរេដបូក ដែលពាក់ព័ន្ធជាមួយប្រព័ន្ធធានាសុវត្ថិភាព និងសវនកម្មនៅក្នុងវិស័យហិរញ្ញវត្ថុ អន្តរកម្មសង្គម និងបរិស្ថាន។

គណៈកម្មាធិការរេដបូកជាតិ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការនេះ ត្រូវធានាប្រសិទ្ធភាពនៃការសម្របសម្រួលតាមវិស័យ ក្នុងចំណោមក្រសួង/ស្ថាប័នខុសៗគ្នា និងរវាងរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ គណៈកម្មាធិការនេះត្រូវសម្របសម្រួលការស្វែងរកធនធាន និងកំណត់អត្តសញ្ញាណ និងលុបបំបាត់ឧបសគ្គនានា ដោយសារតែសមត្ថកិច្ចក្នុងចំណោមក្រសួង និងស្ថាប័នខុសគ្នាផងដែរ។ កិច្ចការនេះអាចសម្រេចបានតាមរយៈ៖

- ការសម្របសម្រួលនិងការបន្សុីគ្នានៃគោលនយោបាយ និងកម្មវិធីនានា ក្នុងចំណោមស្ថាប័ន/វិស័យនានានៃរដ្ឋាភិបាលនៅថ្នាក់ជាតិ ជាពិសេសទាក់ទងនឹងការរៀបចំផែនការរូបវន្ត និងការអនុញ្ញាតឲ្យប្រើប្រាស់ដី
- ការរៀបចំផែនការ និងការសម្របសម្រួលលើការពង្រឹងការអនុវត្តច្បាប់សម្រាប់ការពារដីព្រៃ ជាពិសេស ដែលទាក់ទងនឹងការកាប់ឈើល្មើសច្បាប់ ការប្រើប្រាស់ដី និងការរានឆ្ការដី
- ការសម្របសម្រួលលើការប្រាស្រ័យទាក់ទងជាយុទ្ធសាស្ត្រ និងការចូលរួមនៃអ្នកពាក់ព័ន្ធទាំងអស់នៅកម្ពុជា និងនៅក្រៅប្រទេសដោយ៖
    - o បង្កើត និងអនុវត្តប្រព័ន្ធទំនាក់ទំនងដែលមានប្រសិទ្ធភាព ដើម្បីបង្កើតទំនាក់ទំនងការងារដែលផ្តល់ផល ជាមួយអ្នកពាក់ព័ន្ធនានានៅថ្នាក់ជាតិ និងអន្តរជាតិ
    - o ការសម្របសម្រួលលើការរៀបចំឯកសារជំហរអំពីរេដបូករបស់កម្ពុជា នៅ

ក្នុងការត្រៀមរៀបចំសម្រាប់ការពិភាក្សានៅក្នុងវេទិកាអន្តរជាតិនានា ដែល រួមទាំង ការរក្សាទំនាក់ទំនងនិងការប្រាស្រ័យទាក់ទងបានល្អ និងការចូលរួមនៅក្នុងការចរចាជាអន្តរជាតិ។

## ៧. ធនធានហិរញ្ញវត្ថុ

ធនធានហិរញ្ញវត្ថុសម្រាប់ប្រទេសនានា អាចសំដៅលើការបង់ថ្លៃ ដែលប្រទេសណាមួយទទួលបានសម្រាប់ការអនុវត្តដោយជោគជ័យនូវការកាត់បន្ថយ ឬ ការលុបបំបាត់ដោយជោគជ័យនូវការបំភាយកាបូនពីព្រៃឈើ ដែលត្រូវបានផ្ទៀងផ្ទាត់ ស្របតាមដំណើរការនៅក្រោមអនុសញ្ញា UNFCCC ធៀបនឹង កម្រិតបំភាយយោងព្រៃឈើ /កម្រិតយោងព្រៃឈើ ដែលបានបង្កើត ដោយប្រើប្រាស់ប្រព័ន្ធសុវត្ថិភាពសង្គម និងបរិស្ថានដែលពាក់ព័ន្ធ។ ការរួមបញ្ចូលគ្នារវាងគោលបំណងជាយុទ្ធសាស្រ្ត និងយុទ្ធសាស្រ្តនានា គឺជាភាពចាំបាច់ដើម្បីសម្រេចបានលទ្ធផលរេដបូក។ ទោះជាយ៉ាងណាក៏ដោយ ប្រការសំខាន់គឺត្រូវកត់សំគាល់ផងដែរថា ទោះបី ការទូទាត់ដោយផ្អែកលើលទ្ធផល នឹងត្រូវធ្វើឡើងសម្រាប់ការកាត់បន្ថយការបំភាយ ដែលសម្រេចបានជាក់ស្តែងក៏ដោយ មិនមែនគោលបំណងជាយុទ្ធសាស្រ្ត និងយុទ្ធសាស្រ្តទាំងអស់ សុទ្ធតែសម្រេចបានការកាត់បន្ថយនូវការបំភាយដោយផ្ទាល់ឡើយ។ ឧទាហរណ៍ ការធានាឲ្យមានរចនាសម្ព័ន្ធសម្រាប់អភិបាលកិច្ចល្អដើម្បីអនុវត្តយុទ្ធសាស្រ្តរេដបូកជាតិ គឺជាផ្នែកសំខាន់មួយនៃយុទ្ធសាស្រ្តរេដបូកជាតិ ដែលយុទ្ធសាស្រ្តនេះផ្ទាល់ នឹងមិនសម្រេចបានការកាត់បន្ថយនូវការបំភាយឡើយ និងមិនសម្រេចបានការបង់ថ្លៃឡើយ។ វាគ្រាន់តែជាកត្តាអំណោយផលដ៏សំខាន់មួយដើម្បីទាក់ទាញមូលនិធិសម្រាប់ការអនុវត្តយុទ្ធសាស្រ្តរេដបូកជាតិ នេះតែប៉ុណ្ណោះ។

### ៧.១ អភិក្រមៈ អភិក្រមផ្អែកលើមូលនិធិ

ទោះបីកម្ពុជាបានធ្វើឲ្យមានការរីកចម្រើននៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗកន្លងមកនេះក៏ដោយ ឧបសគ្គជាច្រើនខាងសមត្ថភាពនៅតែបន្តនៅឡើយ រួមផ្សំជាមួយភាពស្មុគស្មាញនៃរេដបូក និងសញ្ញាណនៃការទូទាត់ផ្អែកលើលទ្ធផល អាចនាំឲ្យលទ្ធផលដែលទទួលបាននៅមានកម្រិតទាបជាងការរំពឹងទុក ប្រសិនបើការទូទាត់ផ្អែកលើលទ្ធផល ស្ថិតក្រោមការគ្រប់គ្រងដែលប្រើប្រាស់ត្រឹមប្រព័ន្ធនៅក្នុងប្រទេស។ លើសពីនេះ បទពិសោធន៍នានាបង្ហាញថា មកទល់ពេលនេះ គ្មានប្រទេសណាមួយដែលអនុវត្តរេដបូក ជ្រើសយកវិធីនៃការគាំទ្រថវិកាជាតិ សម្រាប់ការផ្ទេរការទូទាត់រេដបូកឡើយ ប៉ុន្តែតាមរយៈការបង្កើតមូលនិធិរេដបូកដាច់ដោយឡែក ឬ រួមបញ្ចូលរេដបូកទៅក្នុងមូលនិធិវិស័យព្រៃឈើ ឬ ការប្រែប្រួលអាកាសធាតុដែលមានស្រាប់។ ដូច្នេះ អនុសាសន៍ពីការសិក្សាមួយ ដែលធ្វើឡើងដោយក្រុមការងាររេដបូក[xiii]គឺថា វិធីសាស្រ្តដែលផ្អែកលើមូលនិធិ គួរតែត្រូវបានប្រើប្រាស់ ដើម្បីគ្រប់គ្រងការទូទាត់ផ្អែកលើ

DRAFT

លទ្ធផល សម្រាប់រេដបូក នៅក្នុងដំណាក់កាលបណ្ដោះអាសន្នដំបូង ដោយដំណាក់កាលទីពីរជាបន្ត នឹងត្រូវពឹងផ្អែកកាន់តែច្រើនលើប្រព័ន្ធរបស់ប្រទេស និងបន្ទាប់ពីមានដំណាក់កាលអន្តរកាលមួយ។ ទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់វិធីសាស្ត្រដែលផ្អែកលើមូលនិធិ ពុំមានន័យថា ស្ថិតនៅដាច់ចេញពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ប្រទេសទាំងស្រុងនោះឡើយ។ ផ្ទុយទៅវិញ វិធីនេះគួរតែផ្អែកលើសមាសភាគនានាដែលបានបង្ហាញលទ្ធផលវិជ្ជមានរួចទៅហើយ។ នៅក្នុងដំណាក់កាលដំបូង គេអាចប្រើប្រាស់ប្រព័ន្ធគណនីរបស់រដ្ឋាភិបាល ដើម្បីរាយការណ៍អំពីទិន្នន័យនានា ដែលអាចឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្រង់យកទិន្នន័យនេះសម្រាប់ការរៀបចំផែនការទាំងមូល ការលើកថវិកា និងការធ្វើរបាយការណ៍។[xiv]

## ការបង្កើតភ្នាក់ងារជាតិផ្ដល់មូលនិធិរេដបូក

ដើម្បីចាត់ចែងគ្រប់គ្រងវិធីដែលផ្អែកលើមូលនិធិសម្រាប់ការទូទាត់ផ្អែកលើលទ្ធផលសម្រាប់រេដបូក គណៈកម្មាធិការរេដបូកជាតិ ត្រូវសម្របសម្រួលការបង្កើតទីភ្នាក់ងារជាតិផ្ដល់មូលនិធិរេដបូក។ ទីភ្នាក់ងារនេះត្រូវធ្វើការជាមួយប្រភពខុសៗគ្នាដែលមានសក្ដានុពល និងអ្នកប្រើប្រាស់ខុសៗគ្នាជាច្រើន ដោយត្រូវគ្រប់គ្រងជាមួយអ្នកពាក់ព័ន្ធជាច្រើន និងមានគោលបំណងដូចតទៅ៖

១. គាំទ្រដល់ការបង្កើតសកម្មភាពរេដបូក ស្របជាមួយសក្ដានុពលក្នុងការកាត់បន្ថយការបំភាយពីព្រៃឈើ
២. បង្កើតយន្តការផ្ទេរមូលនិធិដែលអាចទុកចិត្តបានជាអន្តរជាតិ ដល់ម្ចាស់ជំនួយ និងវិនិយោគិនដែលមានសក្ដានុពល ដែលមានចំណាប់អារម្មណ៍លើការសម្របសម្រួល ឬ ការទទួលផលពីសកម្មភាពរេដបូក
៣. សម្របសម្រួលការបែងចែកមូលនិធិប្រកបដោយប្រសិទ្ធផល និងធានាឲ្យមានការបែងចែកបានត្រឹមត្រូវនូវការលើកទឹកចិត្តដែលបានពីសកម្មភាពរេដបូក និង
៤. ធានាឲ្យមានការគោរពតាមទិដ្ឋភាពបីនៃប្រព័ន្ធធានាសុវត្ថិភាព៖ ការសន្យាធានាសុចរិតភាពខាងសង្គម និងបរិស្ថាន។

## តួនាទីរបស់ភ្នាក់ងារជាតិផ្ដល់មូលនិធិរេដបូក

ដើម្បីប្រតិបត្តិការឲ្យមានប្រសិទ្ធភាព ភ្នាក់ងារនេះត្រូវមានតួនាទីដូចតទៅ៖

១. គ្រប់គ្រងមូលនិធិរេដបូកដោយខ្លួនឯង ប្រកបដោយវិជ្ជាជីវៈ និងដែលអាចទុកចិត្តបាន នៅក្រៅប្រព័ន្ធថវិការបស់រដ្ឋ ដោយផ្អែកលើប្រព័ន្ធសុវត្ថិភាព និងស្តង់ដារគណនេយ្យភាពដែលអាចទុកចិត្តបាននៅកម្រិតពិភពលោក
២. កៀរគរមូលនិធិពីប្រភពនានាក្នុងវិស័យសាធារណៈ និងឯកជន តាមរយៈការស្វែងរកមូលនិធិជាលក្ខណៈប្រព័ន្ធ តាមកម្មវិធី និងវិជ្ជាជីវៈ

DRAFT

៣. រៀបចំយន្តការផ្ដល់មូលនិធិ៖

ក. គាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ជាពិសេស ផែនការសកម្មភាពរេដបូក

ខ. គាំទ្រដល់គណៈកម្មាធិការរេដបូកជាតិ និងតួនាទីសម្របសម្រួលរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការនេះ

គ. ផ្ដល់មូលនិធិសម្រាប់សកម្មភាពវិនិយោគដែលមានការកំណត់លក្ខខណ្ឌជាមុន ឬ សកម្មភាពដទៃទៀត ដែលរួមចំណែកទៅក្នុងកិច្ចប្រឹងប្រែងនានា ដើម្បីកាត់បន្ថយការបំភាយ និង/ឬ សម្រួលដល់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ

ឃ. ទូទាត់ដល់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ និងក្រុមដទៃទៀត សម្រាប់កិច្ចប្រឹងប្រែង និងលទ្ធផលរបស់ពួកគេនៅក្នុងការបង្កើតលក្ខខណ្ឌ ដែលនាំឲ្យមានការកាត់បន្ថយការបំភាយនៅក្នុងតំបន់របស់ពួកគេ តាមរយៈសកម្មភាពជាយុទ្ធសាស្ត្រ និង/ឬ ការបង្កើតគោលនយោបាយគាំទ្រនានា

ង. គាំទ្រដល់ការកសាងធនធានមនុស្ស និងសមត្ថភាពស្ថាប័ន ដែលផ្ដល់ប្រយោជន៍ដោយផ្ទាល់ និងគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ

៤. ធានាឲ្យមានពិធីសារមួយសម្រាប់ប្រព័ន្ធធានាសុវត្ថិភាពលើការធានាកិច្ចសន្យា និងដែលត្រូវបានអនុវត្តមុននឹងមានការអនុម័តឯកភាពលើសកម្មភាពរេដបូក

៥. ធានាឲ្យមានការអនុវត្ត និងការបំពេញតាមលក្ខខណ្ឌនៃប្រព័ន្ធធានាសុវត្ថិភាព ទោះបីជានៅក្នុងការធានាកិច្ចសន្យា សង្គម ឬបរិស្ថានក៏ដោយ នៅកម្រិតអនុវត្តមុនមានការផ្ដល់មូលនិធិ។

## ៧.២ គោលការណ៍នានា

ផ្អែកតាមធាតុចូលពីអ្នកពាក់ព័ន្ធនានាពីការពិគ្រោះយោបល់នៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ការគ្រប់គ្រងភ្នាក់ងារជាតិផ្ដល់មូលនិធិរេដបូកដែលបានស្នើឡើង គួររួមបញ្ចូលគោលការណ៍ដូចតទៅ៖

- **ប្រសិទ្ធភាព៖** មូលនិធិប្រើប្រាស់សម្រាប់កាត់បន្ថយជាអតិបរមានូវការបំភាយតាមតែអាចធ្វើបាន
- **ប្រសិទ្ធផល៖** មូលនិធិរួមចំណែកកាត់បន្ថយការបំភាយ តាមរបៀបដែលអាចកាត់បន្ថយថ្លៃចំណាយ
- **សមធម៌៖** ការបែងចែកមូលនិធិត្រូវធ្វើឡើងឲ្យបានត្រឹមត្រូវ និងសមធម៌ ជាពិសេស សម្រាប់ជា ប្រយោជន៍របស់ក្រុមដែលងាយរងគ្រោះបំផុត ដូចជា ជន

DRAFT

ជាតិដើម សហគមន៍មូលដ្ឋាន និងស្រ្តី

- **ភាពគ្រប់គ្រាន់៖** ការផ្ទេរមូលនិធិគួរតែធ្វើឡើង នៅពេលត្រូវការជាចាំបាច់ ដើម្បីធានាថា លំហូរនៃផលចំណូល កើតមានស្របគ្នាជាមួយតម្រូវការចំណាយសម្រាប់អនុវត្តយុទ្ធសាស្រ្តរេដបូកជាតិ
- **ភាពបត់បែនបាន៖** មូលនិធិគួរតែគាំទ្រដល់សកម្មភាពខុសៗគ្នា ដែលរួមចំណែកបង្កើនស្តុកកាបូនព្រៃឈើ កាត់បន្ថយការបំភាយ កែលម្អជីវចម្រុះ ការគ្រប់គ្រងព្រៃឈើដោយនិរន្តភាព ទន្ទឹមនឹងមានលក្ខណៈសមស្របទៅនឹងលក្ខខណ្ឌសង្គមសេដ្ឋកិច្ច និងវប្បធម៌នៃទីកន្លែងនីមួយៗ ដែលប្រហែលគ្នានឹងរូបភាពខុសៗគ្នាជាច្រើននៃកម្មសិទ្ធិលើព្រៃឈើ និងសិទ្ធិប្រើប្រាស់ដីព្រៃផងដែរ
- **តម្លាភាព៖** ការគ្រប់គ្រងមូលនិធិ គួរតែស្ថិតនៅក្រោមអង្គភាពកណ្តាលមួយនៅថ្នាក់ជាតិ ដើម្បីប្ញូកសរុបការចំណាយ និងភស្តុភានានា ទន្ទឹមនឹងកំណត់ពីសកម្មភាពនានា ដែលត្រូវទទួលបានការគាំទ្រ ដែលគួរតែធ្វើឡើងតាមរយៈការចូលរួមជាបរិយាប័ន្ននៃអ្នកពាក់ព័ន្ធនានានៅមូលដ្ឋាន ដែលរួមទាំង សហគមន៍មូលដ្ឋាន ក្រុមស្រ្តី និងជនជាតិដើមផងដែរ។

## ៧.៣ យន្តការគណនេយ្យភាពរបស់ភ្នាក់ងារជាតិផ្តល់មូលនិធិរេដបូក

ដើម្បីរក្សាទំនុកចិត្តលើទីភ្នាក់ងារផ្តល់មូលនិធិរេដបូក យន្តការគណនេយ្យភាពមួយនឹងត្រូវដាក់ឲ្យអនុវត្ត ដើម្បីធានាតម្លាភាពជាអតិបរមានៃប្រតិបត្តិការ។ សវនកម្មហិរញ្ញវត្ថុឯករាជ្យនឹងត្រូវធ្វើឡើងជាប្រចាំ។ របាយការណ៍ហិរញ្ញវត្ថុរបស់ទីភ្នាក់ងារផ្តល់ហិរញ្ញវត្ថុរេដបូក និងរបាយការណ៍សវនកម្មសម្រាប់គណៈកម្មាធិការរេដបូកជាតិ នឹងត្រូវចុះផ្សាយ និងមានសម្រាប់ការទទួលបានជាសាធារណៈ។ ប្រធានគណៈកម្មាធិការរេដបូកជាតិ នឹងបញ្ជូនរបាយការណ៍ទាំងនេះទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់គណនេយ្យភាពនៃមូលនិធិនានាដែលបានទទួលតាមរយៈថវិកាជាតិ និង/ឬ ជំនួយឥតសំណង ដែលក្នុងនោះមានកត់ត្រាចំណូលពីរដ្ឋ។

## ៨. ការតាមដាន និងវាយតម្លៃ

ការបង្កើត និងបញ្ជ្រាបក្របខណ្ឌតាមដាន និងវាយតម្លៃ (M&E) សម្រាប់យុទ្ធសាស្រ្តរេដបូកជាតិ គឺជាកិច្ចប្រឹងប្រែងរយៈពេលវែងដែលមានការពាក់ព័ន្ធជាយុទ្ធសាស្រ្ត ដោយសារវានឹងបង្កើតបរិយាកាសអំណោយផល ដោយផ្អែកលើគណនេយ្យភាព និងការរៀនសូត្រ។ ការកែលម្អគណនេយ្យភាព នឹងសម្រួលដល់លទ្ធភាពទទួលបានហិរញ្ញវត្ថុរេដបូកអន្តរជាតិថ្មីៗ ហើយការរៀនសូត្រពីការវិនិយោគនានា នឹងបង្កើតចំណេះដឹង
ថ្មីៗ ដែលមានសារសំខាន់សម្រាប់ការរៀបចំគោលនយោបាយទៅអនាគត ជាពិសេស នៅ

ក្នុងវិស័យព្រៃឈើ។ គោលដៅនៃក្របខណ្ឌតាមដាន និងវាយតម្លៃរបស់ជាតិសម្រាប់យុទ្ធសាស្ត្ររេដបូកជាតិ គឺ៖

- វាស់កម្រិតដែលសកម្មភាពរេដបូកមានប្រសិទ្ធភាពក្នុងការកាត់បន្ថយការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ ទន្ទឹមនឹងរួមចំណែកក្នុងការគ្រប់គ្រងព្រៃឈើឲ្យមាននិរន្តភាព ការបង្កើន និងអភិរក្សស្តុកកាបូនព្រៃឈើ
- តាមដានវិភាគទានពីរេដបូកទៅក្នុងសកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងគោលនយោបាយអភិវឌ្ឍន៍កាបូនទាបនៅកម្ពុជា
- បង្កើតភស្តុតាង និងមេរៀននានា ជាមូលដ្ឋានសម្រាប់ការរៀបចំគោលនយោបាយទៅអនាគត
- សម្រួលឲ្យមានសមាហរណកម្មស៊ីចង្វាក់គ្នានៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃ សម្រាប់យុទ្ធសាស្ត្ររេដបូកជាតិ នៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ជាតិ និងវិស័យសំខាន់ៗ ជាពិសេស នៅក្នុងវិស័យនានាដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ
- ផ្តល់ព័ត៌មានដែលចាំបាច់សម្រាប់បំពេញកាតព្វកិច្ចរាយការណ៍ទៅអនុសញ្ញា UNFCCC និងដៃគូអភិវឌ្ឍន៍ ។

## ៨.១ គោលការណ៍នានា

គោលការណ៍នានាដែលគូសបញ្ជាក់អំពីក្របខណ្ឌ M&E សម្រាប់យុទ្ធសាស្ត្ររេដបូកជាតិ គឺ៖

- **ការប្រើប្រាស់ប្រព័ន្ធ និងនីតិវិធីនានារបស់ជាតិ៖** ក្របខណ្ឌនេះនឹងត្រូវរួមបញ្ចូលជាមួយប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃ របស់ជាតិ។ សូចនាករនានា និងនីតិវិធីតាមដាន នឹងពឹងផ្អែកលើទិន្នន័យដែលបច្ចុប្បន្ននេះកំពុងតាមដានដោយក្រសួងពាក់ព័ន្ធនានា នៅក្នុងករណីសមស្រប។ នីតិវិធីទាំងនេះក៏នឹងស្របគ្នាជាមួយគោលការណ៍ណែនាំរបស់ក្រសួងផែនការសម្រាប់ប្រព័ន្ធ តាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់ជាតិផងដែរ។ ក្របខណ្ឌនេះនឹងផ្អែកលើកិច្ចផ្តួចផ្តើមនានាដែលមានស្រាប់សម្រាប់តាមដាន និងរាយការណ៍អំពីការបំភាយឧស្ម័នផ្ទះកញ្ចក់។
- **ការពង្រឹងគណនេយ្យភាព សមធម៌ និងតម្លាភាព៖** ក្របខណ្ឌនេះនឹងផ្តល់វិធីមួយសម្រាប់ការវាស់វែងអំពីប្រសិទ្ធផល និងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន ដើម្បីសម្រេចបានចំណុចគោលដៅនានា ដូចសមានចែងក្នុងយុទ្ធសាស្ត្ររេដបូកជាតិ និងផែនការសកម្មភាពនៃយុទ្ធសាស្ត្រនេះ ដូច្នេះនឹងជួយកែលម្អគណនេយ្យភាពចំពោះសាធារណជន ស្ថាប័នរដ្ឋ សង្គមស៊ីវិល និងម្ចាស់ជំនួយអន្តរជាតិ។
- **ការលើកកម្ពស់ការរៀនសូត្រតាមបែបចូលរួម៖** ការរៀបចំ និងការអនុវត្តយុទ្ធសាស្ត្រ



DRAFT

វេដប្លុកជាតិ គឺជាការខ្វះខាតថ្មីមួយនៅកម្ពុជា និងលើឆាកអន្តរជាតិ។ ការបង្កើតមូលដ្ឋាននៃភស្តុតាងអំពីអ្វីដែលយុទ្ធសាស្ត្រនានាអាចបង្ហាញថាមានប្រសិទ្ធភាព មានសារសំខាន់ជាសារវន្ត ក្នុងការជូនព័ត៌មានដល់ការរៀបចំគោលនយោបាយទៅអនាគត។ ដូច្នេះ ក្របខណ្ឌនេះនឹងផ្តោតលើការបង្កើតចំណេះដឹង តាមរយៈវិធីសាស្ត្រនៃការចូលរួម និងគាំទ្រដល់ការកំណត់អត្តសញ្ញាណ និងការចែករំលែកមេរៀនដែលទទួលបាន។

- **ការដោះស្រាយបញ្ហាយេនឌ័រៈ** ស្ត្រី និងក្រុមអ្នកក្រខ្សត់នានា ច្រើនតែស្ថិតក្នុងចំណោមអ្នកដែលរងការប៉ះពាល់ធ្ងន់ធ្ងរជាងគេដោយសារផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ក្របខណ្ឌនេះនឹងរួមចំណែកក្នុងការដោះស្រាយសមភាពយេនឌ័រ ការគិតគូរអំពីយេនឌ័រនៅក្នុងសកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការបញ្ជ្រាបយេនឌ័រទៅក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ជាពិសេស ក្នុងវិស័យព្រៃឈើ។

## ៨.២ អភិក្រម

ក្របខណ្ឌការតាមដានត្រួតពិនិត្យ និងវាយតម្លៃសម្រាប់យុទ្ធសាស្ត្រវេដប្លុកជាតិ នឹងត្រូវរៀបចំឡើង ដោយប្រើប្រាស់ទម្លាប់ល្អជាអន្តរជាតិ។ ឯកសារទស្សនទានមួយនឹងត្រូវរៀបចំឡើងដើម្បីគណនា និងកៀងគរធនធានចាំបាច់សម្រាប់ចាប់ផ្តើម យ៉ាងឆាប់រហ័សនូវការរៀបចំក្របខណ្ឌនេះ។ ក្របខណ្ឌនេះនឹងត្រូវរៀបចំរួចរាល់នៅឆ្នាំ ២០១៦ និងត្រូវរួមបញ្ចូលៈ ទ្រឹស្តីអំពីការប្រែប្រួល ក្របខណ្ឌសូចនាករជាមួយទិន្នន័យគោល និងចំណុចដៅនានាសម្រាប់ការឃ្លាំមើលយុទ្ធសាស្ត្រវេដប្លុកជាតិ និងផែនការសកម្មភាពនៃយុទ្ធសាស្ត្រនេះ នីតិវិធីសម្រាប់ការប្រមូលទិន្នន័យ គោលការណ៍ណែនាំសម្រាប់ការវិភាគ និងការធ្វើរបាយការណ៍ គោលការណ៍ណែនាំសម្រាប់ការរួមបញ្ចូលការគ្រប់គ្រងចំណេះដឹង ការរៀនសូត្រ និងការចែករំលែកលទ្ធផល គោលការណ៍ណែនាំសម្រាប់សមាហរណកម្មនៅក្នុងប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធ និងការចាត់ចែងពិស្តារខាងស្ថាប័ន និងយន្តការសម្របសម្រួល។ ផែនការមួយដែលចែងអំពីសកម្មភាពនានា ការអភិវឌ្ឍសមត្ថភាព និងការកំណត់ថ្លៃចំណាយសម្រាប់ការអនុវត្តរយៈពេលវែង និងការបញ្ជ្រាបក្របខណ្ឌនេះ នៅក្នុងក្រសួងពាក់ព័ន្ធ ក៏នឹងត្រូវរៀបចំឡើងផងដែរ។

នៅក្នុងរយៈពេលមធ្យម (២០១៦-២០២០) ក្របខណ្ឌនេះនឹងត្រូវដាក់ឲ្យប្រតិបត្តិការនៅតាមវិស័យនានា ពីសំណាក់ក្រសួងពាក់ព័ន្ធ ហើយសកម្មភាពជាអាទិភាព នឹងត្រូវជ្រើសរើសអាស្រ័យតាមសមត្ថភាព និងធនធានដែលមាន។ ការរួមបញ្ចូលក្របខណ្ឌការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ទៅក្នុងការរៀបចំផែនការនៅមូលដ្ឋានក៏នឹងត្រូវសាក

ល្បងផងដែរ។ ធនធាននឹងត្រូវផ្តល់ឲ្យបានគ្រប់គ្រាន់នៅក្នុងដំណាក់កាលដំបូង សម្រាប់សកម្មភាពមួយចំនួន ដើម្បីបំពេញថ្លៃចំណាយបន្ថែម សម្រាប់អភិវឌ្ឍសមត្ថភាពបច្ចេកទេសសំខាន់ៗអំពីក្របខណ្ឌការតាមដានត្រួតពិនិត្យ និងវាយតម្លៃ សម្រាប់យុទ្ធសាស្ត្ររេដបូកជាតិ ការប្រមូលទិន្នន័យគោល និងការបង្កើតទ្រឹស្តីអំពីការប្រែប្រួល ការរៀនសូត្រ និងការគ្រប់គ្រងចំណេះដឹង។ នៅក្នុងរយៈពេលវែង (ក្រោយឆ្នាំ ២០២១) ក្របខណ្ឌនេះនឹងត្រូវកែសម្រួល ដោយផ្អែកតាមមេរៀនដែលទទួលបាន និងបញ្ជ្រាបទៅក្នុងក្រសួងពាក់ព័ន្ធនានា។

## ៨.៣ ការគ្រប់គ្រង និងការចាត់ចែងស្ថាប័នសម្រាប់ការអនុវត្ត

លេខាធិការដ្ឋាននៃគណៈកម្មាធិការរេដបូកជាតិ ត្រូវសម្របសម្រួលការរៀបចំ និងការអនុវត្តក្របខណ្ឌការតាមដានត្រួតពិនិត្យ និងវាយតម្លៃ នៃយុទ្ធសាស្ត្ររេដបូកជាតិ ។ លេខាធិការដ្ឋាននេះ ក៏នឹងមានភារៈទទួលខុសត្រូវលើការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនៃយុទ្ធសាស្ត្ររេដបូកជាតិ នេះផងដែរ នៅក្រោមការសម្របសម្រួលជាមួយការពិនិត្យវឌ្ឍនភាពប្រចាំឆ្នាំនៃគោលនយោបាយតាមវិស័យពាក់ព័ន្ធ និងគោលនយោបាយជាតិ ដូចជាកម្មវិធីព្រៃឈើជាតិ ។ អង្គភាពមួយ ទទួលបន្ទុកក្របខណ្ឌ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ នឹងត្រូវរៀបចំឡើង នៅក្នុងលេខាធិការដ្ឋាននេះ ដើម្បីសម្របសម្រួលការផ្តោះប្តូរទិន្នន័យ និងការបញ្ជ្រាបក្របខណ្ឌនេះ នៅក្នុងក្រសួងពាក់ព័ន្ធ។ សូចនាករ នីតិវិធី និងការទទួលខុសត្រូវលើការប្រមូលទិន្នន័យ នឹងត្រូវបានឯកភាពគ្នា ជាមួយក្រសួងពាក់ព័ន្ធ វិទ្យាស្ថានជាតិស្ថិតិ និងភាគីដទៃទៀត ដែលមានចំណាប់អារម្មណ៍ក្នុងការចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនេះ។ ភាពជាដៃគូជាមួយគ្រឹះស្ថានសិក្សាស្រាវជ្រាវ សម្រាប់គ្រប់គ្រងបណ្តាញទីតាំងសម្រាប់តាមដានរយៈពេលវែង ក៏នឹងត្រូវសិក្សាផងដែរ។ រចនាសម្ព័ន្ធនេះនឹងអាចប្រើប្រាស់ផងដែរសម្រាប់ចាត់ចែងការសិក្សាវាយតម្លៃម្តងម្កាលអំពីប្រសិទ្ធភាពនៃ យុទ្ធសាស្ត្ររេដបូកជាតិ ដោយផ្អែកលើទិន្នន័យដែលបណ្តាញនេះប្រមូលបាន។

## ៩. សេចក្តីសន្និដ្ឋាន

យុទ្ធសាស្ត្រជាតិរេដបូកកម្ពុជា សង្កត់ធ្ងន់លើតថភាព ដែលការអនុវត្តសកម្មភាពដោយជោគជ័យដើម្បីដោះស្រាយការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ ទន្ទឹមនឹងការរួមចំណែកក្នុងការគ្រប់គ្រងព្រៃឈើដោយនិរន្តភាព ការអភិរក្ស និងពង្រីកស្តុកកាបូនព្រៃឈើ អាស្រ័យជាបឋមលើសកម្មភាពសំខាន់ៗជាបន្តបន្ទាប់ ដែលនាំមកនូវកំណែទម្រង់របៀបធ្វើការតាមទម្លាប់ចាស់ នៅក្នុងការគ្រប់គ្រង និងអភិបាលកិច្ចដីព្រៃនៅកម្ពុជា។ ដោយពិចារណាអំពីកាលៈទេសៈ និងអធិបតេយ្យរបស់ជាតិ ការកែប្រែនៅក្នុងវិស័យព្រៃឈើកម្ពុជា អាចធ្វើទៅបាន តែតាមរយៈការចាត់ចែងឲ្យមានគំរូថ្មីមួយ និងការបង្កើត/ពង្រឹងស្ថាប័ន បទប្បញ្ញត្តិ យន្តការ ទំនាក់ទំនងអន្តរក្រសួង និងប្រព័ន្ធអភិបាលកិច្ចប៉ុណ្

DRAFT

ណោះ។

ប្រការសំខាន់បំផុតគឺថា នីតិវិធីនានាត្រូវតែមានតម្លាភាព ប្រព័ន្ធដែលផ្តល់លក្ខខណ្ឌអំណោយផលត្រូវតែបានពង្រឹង ដើម្បីធានាឲ្យមានគណនេយ្យភាពសាធារណៈ ទិន្នន័យ និងផែនទីត្រូវតែបានធ្វើសមាហរណកម្ម ការសម្របសម្រួលតាមវិស័យនានាប្រកបដោយប្រសិទ្ធភាព និងដែលមានឥទ្ធិពល ត្រូវតែអាចអនុវត្តបាន ក្នុងចំណោមស្ថាប័ននានានៃរដ្ឋាភិបាល នៅតាមរដ្ឋបាលគ្រប់លំដាប់ថ្នាក់។ កំណែទម្រង់ទាំងនេះទាមទារនូវការប្តេជ្ញាចំពោះផលប្រយោជន៍សាធារណៈ ការបើកទូលាយចំពោះបញ្ហាអន្តរវិស័យ ដូចជា យេនឌ័រ និងរេដបូក និងប្រការសំខាន់ជាងនេះទៀតគឺ ចំណាប់អារម្មណ៍ និងការយល់ដឹងរបស់អ្នកពាក់ព័ន្ធនានា។ អ្នកពាក់ព័ន្ធនានាត្រូវមានការលើកទឹកចិត្តឲ្យធ្វើការកែប្រែពីរបៀបធ្វើការតាមទម្លាប់ចាស់ ទើបកម្ពុជាអាចធ្វើការផ្លាស់ប្តូរដោយជោគជ័យទៅរកលំនាំនៃការអភិវឌ្ឍបៃតងជាបរិយាប័ន្ន ដោយកាត់បន្ថយការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ។ នេះជាគោលដៅចុងក្រោយនៃយុទ្ធសាស្ត្រជាតិរេដបូកកម្ពុជា។

## ១០. ឧបសម្ព័ន្ធ

### ឧបសម្ព័ន្ធ ១៖ តារាង និងរូបដែលបានកត់សំគាល់នៅក្នុងអត្ថបទ

**រូបទី ១៖ ធាតុផ្សំសំខាន់ៗទាំងបួន និងការសម្រេចនានា ដែលផ្តល់ការណែនាំអំពីការអនុវត្តរេដបូក**



13/CP.19 គោលការណ៍ណែនាំ និងនីតិវិធីសម្រាប់ការវាយតម្លៃបច្ចេកទេសលើ FRELs សម្រាប់ការដាក់ជូន

12/CP.19 ពេលវេលា និងកម្រិតញឹកញាប់នៃព័ត៌មាន

DRAFT

**តារាងទី ១៖ ដំណើរការពិគ្រោះយោបល់ដែលបានធ្វើឡើងដើម្បីរៀបចំយុទ្ធសាស្ត្រវេដបូកជាតិ**

| **សេចក្តីព្រាងយុទ្ធសាស្ត្រវេដបូកជាតិ** | **កាលបរិច្ឆេទ** |
|---|---|
| គ្រោងឆ្អឹងនៃយុទ្ធសាស្ត្រ | ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៤ |
| សេចក្តីព្រាងដំបូង | ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៤ |
| សេចក្តីព្រាងលើកទីពីរ/ឯកសារសាវតារ | ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៥ |
| កិច្ចប្រជុំពិគ្រោះយោបល់លើកទី១ ជាមួយ TF, TTs, CG, GG | ថ្ងៃទី ២០-២១ ខែឧសភា ឆ្នាំ ២០១៥ |
| សេចក្តីព្រាងលើកទី ៣/ឯកសារសាវតារ | ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ |
| កិច្ចប្រជុំពិគ្រោះយោបល់លើកទី ២ ជាមួយ TF, TTs, CG, GG | ថ្ងៃទី ៦-៨ ខែ កក្កដា ឆ្នាំ ២០១៥ |
| សេចក្តីព្រាងលើកទី ៤/ឯកសារសាវតារ | ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៥ |
| កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិចំនួនបួនលើក ៖<br>ខេត្តក្រចេះ<br>ខេត្តព្រះសីហនុ<br>ខេត្តបាត់ដំបង<br>ខេត្តសៀមរាប<br>**អ្នកចូលរួម** (មន្ត្រីរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលនៅថ្នាក់ខេត្ត សហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើម) | ថ្ងៃទី ០៨-០៩ ខែ កញ្ញា ឆ្នាំ ២០១៥<br>ថ្ងៃទី ១៥-១៦ ខែ កញ្ញា ឆ្នាំ ២០១៥<br>ថ្ងៃទី ២២-២៣ ខែ កញ្ញា ឆ្នាំ ២០១៥<br>ថ្ងៃទី ២៩-៣០ ខែ កញ្ញា ឆ្នាំ ២០១៥ |
| កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ/ ភ្នំពេញ<br>**អ្នកចូលរួម** (មន្ត្រីរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលនៅថ្នាក់ជាតិ ដៃគូអភិវឌ្ឍន៍ TF, TTs, CG និង GG) | សប្តាហ៍ទីបី ខែតុលា ឆ្នាំ ២០១៥ |
| សេចក្តីព្រាងលើកទី ៥/ចុងក្រោយ/ ឯកសារសាវតារ | ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ |
| ការអនុម័តគាំទ្រដោយ MAFF/ MoE/ PM | នៅមុន COP 21, ទីក្រុងប៉ារីស |
| ការធ្វើបទបង្ហាញ/ការផ្សព្វផ្សាយយុទ្ធសាស្ត្រវេដបូកជាតិ នៅក្នុង COP21 | ថ្ងៃទី ៣០ វិច្ឆិកា ដល់ ១១ ធ្នូ ២០១៥ |

DRAFT

សំគាល់៖ **TF**: ក្រុមការងាររេដបូក, **TTs**: ក្រុមបច្ចេកទេស, **CG**: ក្រុមពិគ្រោះយោបល់, **GG**: ក្រុមយេនឌ័រ

DRAFT

## រូបទី ២. យុទ្ធសាស្ត្ររេដបូកជាតិ និងគោលនយោបាយដែលមានស្រាប់តាមវិស័យ និងគោលនយោបាយជាតិ




CONFIDENTIAL

**សំគាល់:**

**NRS**: យុទ្ធសាស្ត្រជាតិរេដបូក; **NFP**: កម្មវិធីព្រៃឈើជាតិ; **NPASMP**: ផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ការពារធម្មជាតិ; **SPFF**: ក្របខ័ណ្ឌ

ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល; **NSDP**: ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ; **RS**: យុទ្ធសាស្ត្រចតុកោណ; **CC**: ការប្រែប្រួលអាកាសធាតុ; **NRM**: ការគ្រប់គ្រងធនធានធម្មជាតិ; **CCCSP**: ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា; **GG**: គោលនយោបាយបាយជាតិអភិវឌ្ឍន៍បៃតង

DRAFT

រូបទី ៣. ចំណាត់ថ្នាក់ដីធ្លី - ការគ្រប់គ្រងដីព្រៃនៅកម្ពុជា[1]



*ផលផល នៃ MAFF*

**ធនធានចម្ការឈើនៅលើដីកសិកម្ម**
កសិ-ឧស្សាហកម្ម៖ ដូងប្រេង កៅស៊ូ។ ល។

**ព្រៃបម្រុងទុកអចិន្ត្រៃយ៍**
សម្បត្តិសាធារណៈរបស់រដ្ឋ
*គ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ*

**ព្រៃបម្រុងទុកអចិន្ត្រៃយ៍**
សម្បត្តិសាធារណៈរបស់រដ្ឋ
*គ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ*

**ព្រៃការពារ**

**ព្រៃសម្រាប់ប្រើប្រាស់ក្នុងគោលបំណងផ្សេងៗ** ដីព្រៃរបស់រដ្ឋដែលនៅទំនេរ/រេចរឹល។ ជំពូកដីបណ្តោះអាសន្ន។ *ទំនងបំផុតថានឹងប្រើប្រាស់ជាដីសម្បទានសង្គមកិច្ច/សេដ្ឋកិច្ច ក្រោយចាត់ថ្នាក់ឡើងវិញជាកម្មសិទ្ធិឯកជនរបស់រដ្ឋ*

**ព្រៃឯកជន**
សម្បត្តិឯកជន *និយ័តកម្ម*
*ដោយរដ្ឋបាលព្រៃឈើ*

រួមបញ្ចូល៖
ព្រៃដាំ
**ព្រៃឈើស្តារឡើងវិញ**

**ធនធានព្រៃឈើនៅលើដីជនជាតិដើម** កម្មសិទ្ធិសមូហភាព នៅក្រោមឈ្មោះសហគមន៍, រដ្ឋបាលព្រៃឈើធ្វើនិយ័តកម្មលើការប្រើប្រាស់
*កំហិតលើការផ្ទេរសិទ្ធិ*

---

[1] ផែនទីបង្ហាញផ្លូវរេដបូកកម្ពុជា ឆ្នាំ ២០១១. សំណើផែនការត្រៀមលក្ខណៈរបស់កម្ពុជាស្តីពីរេដបូក។

DRAFT

រូបទី ៩៖ ការប្រែប្រួលគម្របព្រៃឈើពីឆ្នាំ ១៩៧៦ ដល់ ២០០៦




គម្របព្រៃឈើឆ្នាំ 1976
ផ្ទៃទឹក
ដីមិនមែនព្រៃ
ឫ
ដើមឈើនិង
ម្លាត
ឈើហូបផ្លែនិ
ចម្ការ
ព្រៃកោងកាង
ព្រៃលិចទឹក

ព្រៃ
ស្លឹកម្ជុល
ព្រៃ
ល្បោះ
ព្រៃ
ស្រោង

គម្របព្រៃឈើឆ្នាំ
1997
ដីមិនមែនព្រៃដទៃ
ទៀត
ដើមឈើនិងគុម្ពោត
ចំការឈើ
ព្រៃដុះឡើងវិញ
ព្រៃកោងកាង
ព្រៃលិចទឹក
ព្រៃល្បោះ
ព្រៃចម្រុះ

ព្រៃស្រោង

គម្របព្រៃឈើឆ្នាំ 2002

ដីមិនមែនព្រៃឈើ

ព្រៃដទៃទៀត

ព្រៃល្បោះ

ព្រៃពាក់កណ្តាលស្រោង

ព្រៃស្រោង

គម្របព្រៃឈើឆ្នាំ 2006

ឫស្សី

ដីមិនមែនព្រៃឈើ

ដើមឈើនិងគុម្ពោត

គុម្ពោតឈើស្ងួត

ព្រៃដទៃទៀត

ព្រៃល្បោះ

ព្រៃពាក់កណ្តាលស្រោង

ព្រៃស្រោង

ប្រភព៖ http:/lwww.cambodiaatlas.com/

DRAFT

រូបទី ៥. តំបន់បាត់បង់ព្រៃឈើច្រើននៅកម្ពុជា រវាងឆ្នាំ ១៩៨៨/៨៩ និង ២០០៥/០៦




ប្រភព៖ Brun (2009).

## រូបទី ៦. ការវាយតម្លៃគម្របព្រៃឈើ សម្រាប់ឆ្នាំ ២០០៩-២០១០

| ឆ្នាំ ២០០៩/២០១០<br>ប្រភព៖ រដ្ឋបាលព្រៃឈើ/<br>រាជរដ្ឋាភិបាលកម្ពុជា |  | |
|---|---|---|
| ចំណាត់ថ្នាក់ការវាយតម្លៃគម្របព្រៃឈើជាតិ | សេចក្តីអធិប្បាយ<br>(របាយការណ៍ 2010 FA ITTO/DANIDA) | យោបល់<br>របាយការណ៍ 2010 GRAS) |
| ព្រៃស្រោង | **ព្រៃរងទឹកភ្លៀងតំបន់ទំនាប<br>ព្រៃស្រោងតំបន់ភ្នំ<br>ព្រៃស្រោងស្ងួត<br>ព្រៃជាប់មាត់ទឹក** | តំបន់គ្របដណ្តប់ដោយដើមឈើប្រភេទព្រៃស្រោង |
| ព្រៃពាក់កណ្តាលស្រោង | **ព្រៃចម្រុះរវាងដើមឈើក្នុងពពួកព្រៃស្រោង និងព្រៃល្បោះ** (មានដើមឈើក្នុងពពួក ព្រៃ ស្រោងពី ៣០% ទៅ ៧០% ) | តំបន់ដែលមានប្រភេទឈើចម្រុះនៃពពួកព្រៃស្រោង និងព្រៃល្បោះ |
| ព្រៃល្បោះ | **ព្រៃល្បោះស្ងួតចម្រុះ<br>ព្រៃ Dipterocarp ស្ងួត** | តំបន់គ្របដណ្តប់ដោយដើមឈើប្រភេទព្រៃល្បោះ និងពពួកឈើ Dipterocarp |
| ព្រៃដទៃទៀត | នៅក្នុងចំណាត់ថ្នាក់សម្រេច **ព្រៃកោងកាង ដំណាំកៅស៊ូ និងដូងប្រេង** និង **ឫស្សី** ត្រូវបានរួមបញ្ចូលក្នុងជំពូកនេះ។ ជំពូកនេះក៏រាប់បញ្ចូលផងដែរនូវ៖ **ព្រៃដុះឡើងវិញ ព្រៃតឿ ព្រៃរងការរំខាន** | តំបន់ដែលមានព្រៃប្រភេទផ្សេងទៀត រួមមាន៖ ព្រៃលិចទឹក, ស្មាច់, ព្រៃដុះឡើងវិញ និងចម្ការឈើ ដូចជា *Tectona grandis* ក៏ដូចជា Acacia sp. និង Eucalyptus sp. ផងដែរ លើក |

DRAFT

| | | |
|---|---|---|
| | **ធ្ងន់ធ្ងរ** (ព្រៃដុះដោយ ដុំ ព្រៃដុះឡើងវិញ ព្រៃចំណាស់ និងព្រៃល្បាស់ដុះឡើងវិញ) | លែងតែឈើហូបផ្លែ។ |
| ព្រៃកោងកាង | - | តំបន់សំបូរដោយកោងកាង ពោលគឺប្រភេទដែលធន់នឹងទឹកប្រៃនៅតាមតំបន់ឆ្នេរ |
| កៅស៊ូ | - | តំបន់ដែលបច្ចុប្បន្នកំពុងមានដាំកៅស៊ូ និងដែលបម្រុងទុកសម្រាប់ដាំកៅស៊ូ |
| ឫស្សី | - | តំបន់សម្បូរឫស្សី |

ប្រភព៖ FA, MAFF, 2011

DRAFT

រូបទី ៧. ទិន្នន័យគម្របព្រៃឈើ និងសារពើភ័ណ្ឌព្រៃឈើ ដែលបានធ្វើសម្រាប់រេដបូកនៅកម្រិតគម្រោង



**តារាងទី ២. កត្តានៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើនៅកម្ពុជា**

| | ក្នុងវិស័យព្រៃឈើ | ក្រៅវិស័យព្រៃឈើ |
|---|---|---|
| ផ្ទាល់ | • ការកាប់ឈើដោយគ្មាននិរន្តភាព<br>• ភ្លើងឆេះព្រៃ (តួនាទីមិនទាន់ច្បាស់លាស់)<br>• កាប់អុសដោយគ្មាននិរន្តភាព (តួនាទីមិនច្បាស់) | • ការរានឆ្ការសម្រាប់ធ្វើកសិកម្ម<br>• ការពង្រីកកន្លែងតាំងទីលំនៅ<br>• ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ |

DRAFT

| | | |
|---|---|---|
| ប្រយោល | • ខ្វះការកំណត់ព្រំប្រទល់ដីព្រៃ<br>• ការអនុវត្តច្បាប់មិនបានពេញលេញ<br>• សមត្ថភាពស្ថាប័ននៅទាប និងការអនុវត្តគោលនយោបាយនៅទន់ខ្សោយ<br>• តម្រូវការថាមពលអុសសម្រាប់ប្រើប្រាស់តាមផ្ទះ និងក្នុងឧស្សាហកម្ម<br>• ប្រសិទ្ធភាពទាបនៃចង្រ្កានប្រើអុស និងការប្រើប្រាស់សម្រាប់សាងសង់ និងផលិតថាមពល។ល។<br>• ខ្វះការលើកទឹកចិត្តដែលជំរុញការគ្រប់គ្រងព្រៃឈើឲ្យមាននិរន្តភាព<br>• ខ្វះហិរញ្ញវត្ថុដើម្បីគាំទ្រសកម្មភាពគ្រប់គ្រងព្រៃឈើឲ្យមាននិរន្តភាពដោយស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងសហគមន៍មូលដ្ឋាន<br>• ខ្វះប្រភពផ្គត់ផ្គង់ឈើនិងអុសដែលមាននិរន្តភាព ឬ ប្រភពជំនួស ដែលរួមទាំង ថាមពលអុសដើម្បីបំពេញតាមតម្រូវការ<br>• អភិបាលកិច្ចវិស័យព្រៃឈើនៅទន់ខ្សោយ<br>- ការចូលរួមរបស់អ្នកពាក់ព័ន្ធនៅមានកម្រិតទាប<br>- ខ្វះតម្លាភាព និងគណនេយ្យភាព<br>- ខ្វះការវាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាន | • កំណើនចំនួនប្រជាជន<br>• ភាពក្រីក្រ<br>• កំណើនប្រាក់ចំណូល និងតម្រូវការធនធាន<br>• កំណើនលទ្ធភាពចូលក្នុងតំបន់ព្រៃឈើ<br>• ទិន្នផលកសិកម្មទាប<br>• ការចូលទៅតាំងលំនៅស្ថានក្នុងតំបន់ព្រៃឈើ<br>• ការតាំងលំនៅស្ថានថ្មី រួមទាំងតាមតំបន់ព្រំដែន<br>• ការអភិវឌ្ឍកសិ-ឧស្សាហកម្មខ្នាតធំ (ដែលរួមទាំង សម្បទានដីសេដ្ឋកិច្ច និងសង្គមកិច្ច និងសម្បទានដទៃផ្សេងទៀត)<br>• ការជួញដូរដីធ្លី<br>• តម្រូវការធនធាននៅកម្រិតតំបន់<br>• បទប្បញ្ញត្តិ ESIA នៅទន់ខ្សោយ និងខ្វះការអនុវត្ត<br>• អភិបាលកិច្ច<br>- ភាពមិនច្បាស់លាស់នៃកម្មសិទ្ធិលើដីព្រៃ - ទន់ខ្សោយបំផុតចំពោះតំបន់ដីព្រៃ និងកន្លែងផ្សេងទៀតនៅក្រៅកន្លែងតាំងលំនៅស្ថាន ឬ តំបន់ដាំដំណាំ<br>- ការអនុវត្តច្បាប់នេះនៅទន់ខ្សោយ<br>- ការចុះបញ្ជីដីធ្លីនៅមានកម្រិត (ឯកជននិងរដ្ឋ)<br>- ខ្វះយន្តការដោះស្រាយទំនាស់ឲ្យបានត្រឹមត្រូវ និងតម្លាភាព<br>- ពុំទាន់អនុវត្តការរៀបចំផែនការប្រើប្រាស់ដីឲ្យបានគ្រប់គ្រាន់<br>- ដែនសមត្ថកិច្ចត្រួតគ្នា/មិនច្បាស់លាស់។<br>• និយាមសង្គម (ទាមទារកម្មសិទ្ធិតាមរយៈការប្រើប្រាស់)<br>• អត្ថប្រយោជន៍សេដ្ឋកិច្ចដែលផ្តល់ដោយការគ្រប់គ្រងព្រៃឈើដោយនិរន្តភាពនៅថ្នាក់ជាតិច្រើនតែទាបជាងការប្រើប្រាស់ដីតាមជម្រើស |

DRAFT

| | | |
|---|---|---|
| | | ផ្សេង<br>• ថ្លៃឱកាសនៃការគ្រប់គ្រងព្រៃឈើដោយនិរន្តភាពនៅថ្នាក់មូលដ្ឋាន<br>• ការយល់ដឹងទាបអំពីតួនាទីបរិស្ថាននៃព្រៃឈើ។ |

ប្រភព៖ Cambodia REDD+ Roadmap, 2011. Cambodia Readiness Plan Proposal on REDD+.

DRAFT

# កំណត់សំគាល់

---

[i] គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ឆ្នាំ ២០១៣, កម្មវិធីព្រៃឈើជាតិ ២០១០-២០១៩, គោលនយោបាយបាយជាតិអភិវឌ្ឍន៍បៃតង ២០១៣, សូចនាករតាមដានរួមគ្នា ២០១៤, ផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ការពារធម្មជាតិ (សេចក្តីព្រាងដំបូង ២០១៤), ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល ឆ្នាំ២០១០-២០១៩

[ii] ការពិនិត្យពាក់កណ្តាលអាណត្តិនៃ NSDP បច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣

[iii] ច្បាប់ស្តីពីព្រៃឈើ ២០០២ មាត្រា ៣

[iv] ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ ២០០៨ មាត្រា ៤

[v] ច្បាប់ស្តីពីជលផល ឆ្នាំ ២០០៦ មាត្រា ៣

[vi] កម្មវិធីព្រៃឈើជាតិ ឆ្នាំ ២០១០

[vii] រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០១៤។ សម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

[viii] សន្និសីទភាគីនៃអនុសញ្ញា UNFCCC សេចក្តីសម្រេច 15/CP.19. Par.2

[ix] Broadhead and Isquierdo. 2010 (Draft). Assessment of land use, forest policy and governance in Cambodia. FAO

[x] Cambodia REDD+ Roadmap, 2011. Cambodia Readiness Plan Proposal on REDD+.

[xi] Cambodia REDD+ Roadmap, 2011. Cambodia Readiness Plan Proposal on REDD+

[xii] ផែនទីដែលមានស្រាប់សម្រាប់ឆ្នាំ ២០០៦ និង ២០១០ មានតែ ៨ ជំពូកប្រើប្រាស់ដី/ចំណាត់ថ្នាក់។ ផែនទីថ្មី ឆ្នាំ ២០១៤ ត្រូវបានផលិត ដោយមាន ២២ ថ្នាក់។ ផ្នែកនានានៃចំណាត់ថ្នាក់ប្រើប្រាស់ដី/គម្របព្រៃឈើ ត្រូវបានប្រើប្រាស់ក្នុងផែនទីថ្មីឆ្នាំ ២០១៤។

[xiii] Pesti, B., Fach, E., Chhun, D., Boyle, T. 2014. Designing transparent and accountable fund management arrangement for REDD+ in Cambodia.

[xiv] Ibid Pesti et al. 2014.

DRAFT